# ពេលវេលានៃការរួបរួម និងទីសម្គាល់

ទិវាសួស្ដី។ ជាឯកសិទ្ធដែលនៅទីនេះយប់នេះ និងឈរនៅត្រង់នេះ។

2 ខ្ញុំ នៅវេលាព្រឹកនេះ បានចុះពីលើថ្នល់មក...ខ្ញុំអធិស្ឋានរង់ចាំព្រះអម្ចាស់។ ហើយបានចុះមកតាមផ្លូវ ខ្ញុំបានបើក—វិទ្យុព័ន្ធការី បងប្រុសស្មីត បងប្រុសស្បែកខ្មៅ (តើអ្នកបានឮគាត់និយាយទេព្រឹកនេះ? មានទេអ្នកទាំងអស់គ្នា?) គឺថាខ្ញុំជឿវាអូហៃយ៉ូ។ មានអ្នក ប្រាប់ខ្ញុំអំពីសេចក្ដីអធិប្បាយរបស់គាត់ និងនិយាយថា "អ្នកគួរតែស្ដាប់គាត់ ដូច្នេះដែរ។"

3 ខ្ញុំបានស្ដាប់នូវអ្វីដែលគាត់បាននិយាយ នៅព្រឹកនេះ។ គាត់បានប្រាប់ពីអំពើបាបដែលបានចងនៅលើពិភពលោកសព្វថ្ងៃនេះគឺគាត់...ហើយខ្ញុំ បានបើកទៅប៉ុស្ដិ៍ផ្សេងមួយទៀត និងឮអ្វីផ្សេងទៀត។ នៅពេលនោះខ្ញុំបានចុះមកទីនេះ ខ្ញុំបានត្រៀមរួចហើយ ឃើញទេ វាមិនមែនជាការឃើតយ៉ាវទេ ក្នុងការមកព្រះវិហារព្រឹកនេះនៅពេលដែលខ្ញុំមកដល់ខាងក្នុង។ ដូច្នេះយើង ពិតជាមានឯកសិទ្ធ យប់នេះនៅទីនេះ និងបានបម្រើនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់។

4 ហើយ និយាយអំពីបងប្រុសនេវីល និងសារនៅថ្ងៃផ្សេងទៀត ទាក់ទងជាមួយស្ដ្រីតូចម្នាក់នេះ បងស្រីដែលបានចាកចេញពីយើងទៅ។ គឺយើងទាំងអស់គ្នាស្គាល់គាត់ គឺបងស្រី វីវើរ។ ហើយគិតពីបុរសម្នាក់ដែលនៅទីនេះ ដែលទទួលពិធីជ្រមុជទឹកនូវវេលាយប់នេះ គាត់...ខ្ញុំជ្រមុជទឹកឲ្យគាត់នៅក្នុងអាងទឹកនៅពេលដែលខ្ញុំ...គឺគេត្រូវនាំគាត់មកទីនេះដោយរទេះរុញ។ គាត់ស្ទើរតែស្លាប់ ដោយសារជំងឺមហារីក ហើយគាត់មានតែយប់នេះដើម្បីរស់នៅ គ្រូពេទ្យបានបោះបង់គាត់ចោល ហើយ គាត់នឹងស្លាប់នៅព្រឹកបន្ទាប់។ ហើយខ្ញុំបានទៅសួរសុខទុក្ខគាត់ ហើយខ្ញុំបានព្យាយាមនិយាយពីការព្យាបាលពីព្រះទៅកាន់គាត់ ហើយគាត់គ្រាន់តែបន្ត ការនិយាយតាម គាត់បាននិយាយថា "ខ្ញុំ មិនសមនឹងលោកអញ្ជើញចូលក្នុងផ្ទះខ្ញុំទេ។" គាត់បាននិយាយថា "លោកម្ចាស់ខ្ញុំ—ខ្ញុំប្របាទមានឋានៈទន់ទាបណាស់ មិនសមនឹងលោកអញ្ជើញចូលក្នុងផ្ទះខ្ញុំទេ។" គាត់បន្ថែមថា "ខ្ញុំគឺជាមនុស្សមានបាប។" ប៉ុន្ដែគាត់បាននិយាយថា "ខ្ញុំមិនចង់ស្លាប់បែបនេះឡើយ។" ហើយក្រេសវេបប៊ី (Grace Weber) នៅទីនេះ បាននាំខ្ញុំមក ដល់ទី

នេះ។ ខ្ញុំទើបតែបានចូលមក ខ្ញុំបានអស់កម្លាំងពីការប្រជុំ ហើយនៅកន្លែង នោះ ហើយ ដែលខ្ញុំបានកំពុងតែអធិស្ឋានឲ្យគាត់ នឹងបានអានបទគម្ពីរឲ្យគាត់ ហើយ គាត់ បានទទួលការសង្គ្រោះ។ បន្ទាប់មក គាត់ពិតជាពិបាកលើដៃរបស់ គាត់ទ្បើង ប៉ុន្តែ គាត់ចង់ចាប់ដៃគ្រប់គ្នា។ គាត់គ្រាប់តែ...អ្វីមួយបានកើតឡើង ចំពោះគាត់។

5 ហើយខណៈពេលដែលពួកគេកំពុងចាប់ដៃ ខ្ញុំបានឃើញនិមិ្មតគាត់បានក្លាយ ទៅជាទ្រុងសត្វមាន់ បានត្រឡប់មកវិញ។ ខ្ញុំបាននិយាយថា "មិនអីទេ រឿងនេះ នឹងល្អប្រសើរនាពេលនេះ" ហើយរឿងនោះកើតកាលពី១៨ឆ្នាំ កន្លងទៅហើយ។ គាត់បានកើតជំងឺមហារីកនោះពីមុនមកហើយ។ ប្រសិនបើគាត់...ស្លាប់ គាត់មិន ស្លាប់ជាមួយនឹង ជំងឺមហារីកទ្បើយ គាត់មានជំងឺគាំបេះដូង ហើយជំងឺនេះបាន សម្លាប់គាត់។ គាត់ត្រូវបានគេដាក់ខ្យល់អុកស៊ីសែន គាត់បានស្លាប់ដោយសារ ជំងឺគាំងបេះដូង។

6 ហើយបន្ទាប់មក ខ្ញុំបានកំពុងតែគិត នៅពេលចុងក្រោយ នៅពេលមនុស្ស ទាំងអស់បានដើរចេញ ហើយពួកគេបានច្រៀង *ព្រះយេស៊ូយាងចូលមក*។ នោះ ហើយគឺជាអ្វីពិតជាបានកើតមានឡើង ទ្រង់បានយាងមក ហើយបានរក្សា ជីវិតរបស់គាត់ រយៈពេល១៨ឆ្នាំ។ ហើយខ្ញុំបានគិតថា គួរឲ្យកោតស្ញប់ស្ញែង យ៉ាងណា។ ស្ត្រីម្នាក់នោះ ប្រហែលជាមិនដឹងថា គាត់កំពុងតែធ្វើរឿង បែបហ្នឹង ឡើយ។ បន្ទាប់មកទៀត គាត់ប្រហែលជាបានធ្វើបែបនោះ។ ប៉ុន្តែ ថាតើគួរឲ្យ ស្ញប់ស្ញែងយ៉ាងណា ដែលមានចម្រៀង *បន្ទាប់មកព្រះយេស៊ូបានយាងមក* នៅ ទីនោះ។

7 ឥឡូវនេះ វាគឺជារឿងបើកឆាកបន្តិច ខ្ញុំ—ខ្ញុំសង្ឃឹមថា យើងមានពេលវេលា ដ៏អស្ចារ្យក្នុងការប្រជុំនេះ។ ខ្ញុំមានអារម្មណ៍ភ័យ។ នៅព្រឹកនេះខ្ញុំមានអារម្មណ៍ រំភើប ខ្ញុំបានចាប់ផ្ដើម—អធិស្ឋាន។ ហើយខ្ញុំ—ខ្ញុំត្រឡប់មកផ្ទះវិញ។ ក្រុមគ្រួសារ ទើបតែបាននាំគាត់ ទៅកាន់អារីសូណា (Arizona) ហើយខ្ញុំ...ដូចជាកូនក្មេង បំផុតទៅសាលារៀន។ ហើយខ្ញុំត្រឡប់មកវិញនៅទីនេះ គ្រាន់តែដើម្បី—ដើម្បី សម្រាក ទៅបរបាញ់សត្វជាមួយប្អូនប្រុស វ៉ូដ (Wood) ហើយជាមួយនឹង បងប្អូន ប្រុសមួយចំនួននៅទីនេះ ទៅបរបាញ់សត្វ សម្រាប់សប្តាហ៍ក្រោយនេះ។ យើង នឹង ទៅកាន់កេនតាកគី (Kentucky)។ ហើយខ្ញុំបាន...ទៅដល់...ខ្ញុំទើបតែទទួល បាន បទពិសោធនៅថ្ងៃនោះដែល—ដែលលោកស្រី វេវើ (Weaver) បានស្លាប់ វា

គឺជាពេលដែលខ្ញុំបាននៅទីនោះ ខ្ញុំគួរតែបាននៅទីនេះ ហើយជួយប្អូនប្រុសនេវីល (Neville) នៅក្នុងពិធីបុណ្យសពនោះ។

8 ហើយ ខ្ញុំមិនបានព្យាយាមដើម្បី...ខ្ញុំមិនបានព្យាយាមដើម្បី—ដើម្បីនិយាយច្រើនអំពីរឿងនេះទេ អ្នកដឹងទេ មនុស្សនៅជុំវិញនេះបានត្អូញត្អែ។ ពីព្រោះ ខ្ញុំគិត ថារឿងមួយដែលអាក្រក់បំផុតគឺឃើញ—មនុស្សប្រុសឬក៏ស្ត្រីដែលនៅតែត្អូញត្អែរ។ ខ្ញុំតែងតែគិតថា "ព្រះជាម្ចាស់ សូមកុំឲ្យខ្ញុំគិតពីរឿងនេះឡើយ។" ឃើញទេ ដែល—ជំនឿដែលចុះខ្សោយកើតមានគ្រប់ពេល អ្នកដឹងទេ។ អ្នកគ្រាន់តែ—អ្នកគ្រាន់តែ...ប្រសិនបើ អ្នក—ប្រសិនបើអ្នក...ខ្ញុំបានដឹងថានៅ ពេលដែលពួកគេគាន់តែចាស់ទៅៗម្នាក់ក្នុងចំណោមពួកយើងយើងនឹងមានរឿងអ្វីមួយកើតឡើង ហើយមានរឿងមួយកើតមានឡើង។ ហើយខ្ញុំដឹងថា រឿងដ៏ តិចតួចនោះ នឹងនៅតែកើតឡើងជាបន្តបន្ទាប់ នៅពេលដែលអ្នកកាន់តែចាស់ទៅៗ ពួកគេនឹងទទួលបានរឿងបែបនោះ។ ប៉ុន្តែខ្ញុំគិតថារឿងដែលអាក្រក់បំផុតគឺសម្រាប់ សាតាំង គ្រប់គ្រងលើជីវិតរបស់មនុស្សមួយចំនួនៈ ជាមនុស្សប្រុសចាស់ ឬមនុស្សស្រីចាស់ដែលព្ញកែរអ៊ូ អ្នកឃើញទេ។ ខ្ញុំ—ខ្ញុំសង្ឃឹមថា ខ្ញុំមិនទទួល បានរឿងបែបនោះឡើយ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងយកឈ្នះបន្ទុករបស់ខ្ញុំបាន ហើយ—ហើយបានទៅដល់ចំនុច... ខ្ញុំចង់ឲ្យជីវិតរបស់ខ្ញុំគ្រប់គ្រងដោយសិរីរុងរឿងរបស់ព្រះ យូរអង្វែង ភាពស្លូតបូត សន្តិភាព ការបន្ទាបខ្លួន ហើយបំពេញជាមួយ នឹងព្រះវិញ្ញាណបរិសុទ្ធ។

9 ហើយខ្ញុំ...រឿងដ៏ចំបងមួយដែលតែងតែធ្វើឲ្យខ្ញុំឈឺចាប់ ក្នុងមួយជីវិតរបស់ ខ្ញុំ គឺស្ថានភាពភ័យខ្លាច។ នោះគឺនៅពេលខ្ញុំខូចចិត្ត បន្ទាប់មកខ្ញុំពិត ជាអស់កម្លាំង។ ខ្ញុំទទួល...ជាប្រភេទនៃអារម្មណ៍ដូចជាគ្មាននរណា យកចិត្តទុក ដាក់ចំពោះអ្នក អ្នកដឹងទេហើយ—ហើយអ្នកទាំងអស់គ្នា...អ្នកក៏មានដែរ។ ហើយវាកើតឡើងចំពោះខ្ញុំហួសកម្រិត អ្នកដឹងទេ ពេលខ្លះ វាពិតជាអាក្រក់ណាស់ ហើយខ្ញុំមិនអាចទ្រាំបានទេ...វាគឺជាភាពតានតឹង នោះហើយរឿងបែបហ្នឹង។ ហើយខ្ញុំបានសម្គាល់ រឿងនោះជាច្រើនដង ជាពិសេសជា មួយនឹងនិម្មិតអស់ទាំងនោះអ្នកឃើញទេ រឿងនេះបានចូលមកកាន់ខ្ញុំ។ ខ្ញុំ មើលទៅកាន់មនុស្សម្នាក់ ខ្ញុំគិត "នេះគឺជានិម្មិតមួយ។ ទេ ទេ ទេ វាមិនមែនជានិម្មិតទេ បាទ! វាមិនមែនជានិម្មិតទេ?" អ្នកឃើញទេ? ហើយអ្នកមិនបានដឹងពីតម្លៃនៃនិមិត្តនោះនោះទេ។ ដូច្នេះហើយ បន្ទាប់មក—ដូច្នេះបន្ទាប់មកអ្នក—អ្នកមានចម្ងល់។ បន្ទាប់មកអ្នកនឹងគិតពីការ

នេះ "ហ្នឹង អ្នកគឺ..." បន្ទាប់មក អ្នកគិតពីជីវិតរបស់អ្នក ហើយនិយាយថា "បាទ ឥឡូវ... តើ—តើខ្ញុំបានធ្វើអ្វី? ខ្ញុំនៅទីនេះ ខ្ញុំ—ខ្ញុំមានអាយុ៥០ឆ្នាំ ហើយខ្ញុំមិនបាន ធ្វើអ្វីសោះសម្រាប់ព្រះជាម្ចាស់ ហើយខ្ញុំ—ខ្ញុំកាន់តែចាស់ ទៅៗ។ ហើយតើអ្វី...? អូ ខ្ញុំអើយ។" ក្រោយមកអ្នកទទួលបាន...អ្វីដែល យើងធ្លាប់ហៅថា "ធ្លាក់ទឹកចិត្ត" បងប្អូនមួយចំនួនដែលមានអាយុប្រហាក់ប្រ ហែលនឹងខ្ញុំ ចាំពីអ្វីដែលពួកគេធ្លាប់ បានហៅថា "មានការធ្លាក់ទឹកចិត្ត។" ផប់ធ្លាប់បាននិយាយអំពីពាក្យនេះ ហើយ ខ្ញុំបានឆ្ងល់ថា តើគាត់ចង់មានន័យ យ៉ាងដូចម្ដេច ហើយខ្ញុំយល់ប្រាកដនៅពេល នេះ ថាតើគាត់ចង់មានន័យដូចម្ដេច។ ដូច្នេះបន្ទាប់មក អ្នកនឹងមានអារម្មណ៍បែប ដូចនោះ ដែលមិនមានអ្វីជាការពិតទេ នោះគឺជាអ្នក អ្នកដឹងទេ។ ឃើញទេ អ្នកដឹង គឺជាអ្នកដែលគិតបែបនោះ។

10 ដូច្នេះហើយ ខ្ញុំបានព្យាយាមធ្វើឲ្យខ្លួនឯង ស្ងប់ស្ងាត់បន្តិចនៅពេលនេះហើយ ត្រៀមខ្លួនរួចជាស្រេចសម្រាប់—យុទ្ធនាការដ៏ធំទាំងនោះដែលខ្ញុំសង្ឃឹមថា នឹង មកដល់ក្នុងពេលឆាប់ៗនេះ។ បន្ទាប់មក តាមរយៈ...ខ្ញុំត្រូវតែទៅកាន់ ញ៉ូយ៉ក (New York) នៅពេលនេះ ហើយខ្ញុំ...ចូលរួមកិច្ចប្រជុំមួយ នៅទីនោះ ជាការបោះ ជំរុំ មួយ។ ហើយបន្ទាប់មក ទៅកាន់ ស្រ៊ីវីផត (Shreveport) បន្ទាប់មក ត្រឡប់ ទៅកាន់ ផូនីច (Phoenix)។ បន្ទាប់មក ទៅជុំវិញ ភាគខាងលិច...ភាគខាងត្បូង សហ រដ្ឋអាមេរិក។ ហើយបន្ទាប់មក ពួកគេបានធ្វើការរៀបចំសម្រាប់ ការចេញទៅ បរទេសឥឡូវនេះ ចាប់ផ្ដើមឲ្យលឿនបំផុតតាមដែលអាចធ្វើបាន បន្ទាប់ពីឆ្នាំទីមួយ ប្រហែលជានៅក្នុងខែ មិនា មេសាប្រហែលជាពេលហ្នឹងកន្លែងដែលអ្នកចាប់ផ្ដើម ស្តុកហូម (Stockholm) ឬក៏អូស្លូ(Oslo) ហើយ ទៅជុំវិញពិភពលោក ប្រសិនបើ យើងអាចធ្វើ បាន នៅក្នុងដំណើរកំសាន្ត ក្រោយទៀត។

11 ហើយឥឡូវនេះ ខ្ញុំស្នាក់នៅផ្ទះ ជាការសម្រាកបន្តិចបន្តួច ដើម្បីឲ្យខ្លួនខ្ញុំ បានសម្រាក ហើយនឹងទទួលបានសុខភាពល្អ។ ហើយប្រសិនបើជាបំណងព្រះ ហឫទ័យព្រះ ខ្ញុំនឹងត្រឡប់មកវិញនៅអាទិត្យក្រោយ ពីគេនតាក់គី (Kentucky) ហើយ—ហើយ ប្រសិនបើមិនអីទេ ជាការសព្វព្រះហឫទ័យពីព្រះ ហើយប្អូនប្រុស នីវីលី(Neville)បាទខ្ញុំនឹងធ្វើការសាកល្បងចែកចាយ នៅថ្ងៃអាទិត្យក្រោយ ប្រសិនបើ—ប្រសិនបើជាបំណងព្រះហឫទ័យរបស់ព្រះ។ ហើយប្រសិនបើ ទ្រង់ មានបំណងព្រះហឫទ័យដូចជាប្អូនប្រុស នីវីល (Neville) នោះ ខ្ញុំ—ខ្ញុំនឹងនៅ

ទីនេះ។ បាទលោក ទ្រង់គ្រាន់តែ...ប្រសិនបើ ទ្រង់មានបំណង ព្រះហឫទ័យដូច នឹងប្អូនប្រុស នីវីល (Neville)។ ខ្ញុំសង្ឃឹមថាទ្រង់នឹងមាន បំណង ព្រះហឫទ័យ បែបនោះចុះ។ ឥឡូវនេះ ឃើញទេ ក្រោយមក ខ្ញុំដឹងថា ខ្ញុំក្នុងពេលឆាប់ៗ នេះ ប្រសិនបើជាបំណងព្រះហឫទ័យរបស់ព្រះ ខ្ញុំនឹងចាកចេញពីអ្នក នៅក្នុង ពេលដ៏ខ្លីនេះ។

12 ហើយ ខ្ញុំ...គ្រាន់តែចែកចាយតិចតួច ដូចជាខ្ញុំបានជ្រើសរើសអ្វីមួយដ៏តូច ចេញពីបេះដូងរបស់ខ្ញុំ បន្ទាប់មកខ្ញុំ—ខ្ញុំ—ខ្ញុំមានអារម្មណ៍ចង់បង្ហាញវា ទៅកាន់ អ្នក អ្នកឃើញទេ ហើយអ្នកអាចប្រកបគ្នាបាន។ ពេលនេះ ខ្ញុំបានទទួល សារមួយ ចំនួនពីការនេះ ប្រាំ ឬប្រាំមួយអ្នកដែលមកកាន់ខ្ញុំនៅប៉ុន្មានថ្ងៃចុងក្រោយនេះ។ ហើយខ្ញុំបានមកទីនេះ អស់រយៈពីរថ្ងៃហើយ ខ្ញុំកំពុងបរបាញ់កំប្រុកនៅទីនេះ។ ហើយខ្ញុំបានដើរចូលព្រៃ ហើយមានក្រដាសនិងខ្មៅដៃ។ ឃើញទេ? ពេលនេះ ប្រហែលជាពេលដ៏ល្អ នឹងជាថ្ងៃដ៏ល្អ ខ្ញុំបានប្រមូលដើមឈើដាក់មួយ កន្លែង។ ប្រសិនបើខ្ញុំមិនចូលគេងទេ ខ្ញុំនឹងចាប់ផ្ដើមអធិស្ឋានហើយបន្ទាប់មក ព្រះជាម្ចាស់ នឹងប្រទានអ្វីមួយដល់ខ្ញុំ ខ្ញុំចាប់ផ្ដើមកត់ត្រាពីការនេះ អ្នកឃើញទេ។ អ្នកយល់ពី អ្វីដែលខ្ញុំចង់និយាយទេ ពេលដែលអ្នកទៅដល់ដោយខ្លួនឯង ហើយបន្ទាប់មក អ្នក...ក្រោយមកខ្ញុំបានចូលមកនៅទីនេះ សរសេរពីការនេះឡើង ទាំងអស់នៅលើ ក្រដាសមួយសន្លឹក។ ហើយក្រោយមក នៅពេលខ្ញុំត្រូវបានហៅ ខ្ញុំរត់ចេញមកក្រៅ ហើយយកក្រដាសរបស់ខ្ញុំនឹងមើលតាមរយៈវានិងឃើញពីអ្វីដែលខ្ញុំនឹងចាប់ផ្ដើម សរសេរ អ្នកឃើញទេ។ នោះហើយគឺជាអ្វីដែលទើបតែ បានកើតឡើង។

13 ដូច្នេះឥឡូវនេះ ខ្ញុំចង់ ប្រសិនបើជាបំណងព្រះហឫទ័យរបស់ព្រះ ជាម្ចាស់ ដើម្បី និយាយគ្រាន់តែ...ខ្ញុំព្យាយាមបង្កើត...បំបែកវាទៅជាផ្នែកធំៗ ព្រះបន្ទូលដ៏ វែង អ្នកឃើញទេ វាធ្វើឲ្យអ្នកចំណាពេលយូរម៉ោង។ ហើយ ព្រះជាម្ចាស់បានជួយ ខ្ញុំធ្វើការដ៏ខ្លីមួយនៅឈីកាហ្គោ(Chicago)ជាយប់ចុងក្រោយនៅទីនេះប្រហែលជា សាបសិបនាទី។ ហើយមានមនុស្សមកជុំវិញនេះនិយាយថា "ខ្ញុំមិនគិតអ្នកអាចធ្វើ វាបានទេ ប៉ុន្តែអ្នកធ្វើវាបាន!" ដូច្នេះហើយ សាមសិបនាទី គិតចាប់ប្រហែលពីម៉ោង ពីរ នឹងកន្លះ ម៉ោង ឬក៏បីម៉ោង អ្នកដឹងទេ។ ដូច្នេះ យប់នេះខ្ញុំត្រូវតែប្រញាប់ និង អនុវត្តបន្តិច មិនឲ្យអ្នកនៅចាំយូរនោះទេ។

14 សូមព្រះប្រទានពរអ្នក។ មិនថាខ្ញុំទៅដល់ទីណាទេ មិនមានកន្លែងណាដូចជារោងឧបោសថនេះឡើយ។ វាគឺជាផ្ទះ ផ្ទះដ៏កក់ក្ដៅ។ ហើយ ខ្ញុំមានការអាណិតអាសូរ ចំពោះគ្រួសាររបស់វេវើ (Weaver)។ ហើយ ប្អូនប្រុសដ៏មានតម្លៃបានស្លាប់ ខ្ញុំបានអធិស្ឋានជាមួយគាត់ ក្នុងពេលដ៏ខ្លី មុនពេលដែលគាត់បានចាក់ចេញទៅ ហើយជាចរិកលក្ខណៈដ៏ល្អ។ ហើយគាត់ក្នុងដំណាក់ជាមួយព្រះនៅពេលនេះ ហើយ អ្វីៗទាំងអស់គឺចប់សព្វគ្រប់អស់ហើយ។ ហើយ យើងនឹងទៅកាន់ដំណាក់របស់ ព្រះអង្គដោយរបៀបណាមួយ ហើយយើងគ្រប់គ្នាបានដឹងពីការនោះហើយ។ ដូច្នេះហើយ យើង..សូមឲ្យព្រះដាក់ព្រលឹងពួកគេសម្រាកនៅក្នុងភាពសន្តិភាពជាមួយនឹងព្រះជាម្ចាស់ ហើយ ថ្ងៃណាមួយយើងសង្ឃឹមថានឹងចូលរួមជាមួយដែនដីនៅឯនាយ ជាកន្លែងដែល គ្មានជំងឺ គ្មានការឈឺចាប់ ឬក៏សេចក្ដីស្លាប់ឡើយ។ រហូតទាល់តែដល់ពេលនោះ សូមយើងធ្វើគ្រប់រឿងទាំងអស់ដែលយើងអាចធ្វើទៅបានសម្រាប់ដំណឹងល្អ។

15 បើនិយាយពីភាពតានតឹង ខ្ញុំបានកំពុងតែអធិស្ឋាននៅព្រឹកនេះ។ តើអ្នកនឹងធ្វើអ្វី ប្រសិនបើ អ្នកមិនមានភាពតានតឹង? សូមគិតពីការនេះ។ ភាពតានតឹងគឺជាផ្នែកមួយនៃការ រស់នៅ។ ជាប្រភេទនៃការលើកទឹកចិត្តខ្ញុំ នៅពេលដែលខ្ញុំ គិតពីការនោះ។ ប្រសិនបើ អ្នកមិនមានបញ្ហាទេ អ្នកនឹងដូចជា មនុស្សតុក្កតា អ្នកនឹងមិនមាន អារម្មណ៍។ មិនមានអ្វីមួយនឹងកើតឡើងឡើយ។ ដូចប្ដីប្រពន្ធមួយគូរ ប្រសិនបើ គាត់ចង់ធ្វើអ្វីមួយ ហើយពួកគេព្យាយាមធ្វើជាមួយគ្នា (ជាពិសេសគ្រីស្ទាន) ហើយម្នាក់ទៀតចង់ធ្វើ...បន្ទាប់មក នៅពេលដែលអ្នករួម គ្នាតែមួយដើម្បី...អ្នកនឹងរកឃើញអ្វីដែលនាងបានធ្វើ នាងក៏បានរកឃើញ...ឃើញទេ បញ្ហាពិតជាបាននាំអ្នកឲ្យកាន់តែជិតស្និទ្ធជាមួយគ្នា។ ហើយ មានមនុស្សម្នាក់ ប្រាប់អ្នកថា "ល្អ" "គ្រាន់តែគិតពីប្រពន្ធ ដែលទទួលរងនូវបញ្ហា ជាច្រើន នៅពេលដែលអ្នកធ្វើរឿងមិនល្អ ឬក៏ជាស្វាមីដែលទទួលរងនូវបញ្ហាខ្លះ នៅពេលអ្នកធ្វើរឿងមិនល្អ។ បន្ទាប់មក នៅពេលអ្វីៗទាំងអស់ត្រូវបានអត់ទោស មើលថាតើអ្នកមានអារម្មណ៍ចំពោះគាត់យ៉ាងណា។ អូ ខ្ញុំអើយ អ្នកគ្រាន់តែ..." ឃើញទេ អ្នកគ្រាន់តែទទួលយកនូវបញ្ហា។ គឺជាការស្រេច។

16 ហើយ គ្រាន់តែគិត ពីអារម្មណ៍ ប្រសិនបើអ្នកមិនមានអារម្មណ៍ គ្មានការឈឺ ចាប់ ឬក៏ គ្មានអារម្មណ៍អ្វីទាល់តែសោះ? ប្រសិនបើ មិនមានការឈឺចាប់

ទាល់តែ សោះ? អ្នកមិនមានអារម្មណ៍ទាល់តែសោះ។ ឃើញទេ? ហើយ ប្រសិនបើអ្នក គ្មានអារម្មណ៍ ក្រោយមកកោសិការរបស់អ្នកមួយនឹងត្រូវបាត់បង់។ ឃើញទេ? ដូច្នេះហើយគ្រប់ការទាំងអស់កើតឡើងសម្រាប់ការល្អ។ ដូច្នេះ "ព្រះជាម្ចាស់បានប្រទានព្រះគុណដល់យើងដើម្បីឈររឹងមាំជាមួយបញ្ហានេះ"គឺរឿងដូចនោះហើយ។ ប្រសិនបើយើងមានជំហរមាំជាមួយនឹងព្រះគុណនោះ ហើយនឹង ឈររឹងមាំ និងនិយាយថា "យើងដឹងថានៅពេល ដែលយើងអស់ជីវិតទៅមានជីវិតដ៏អស្ចារ្យមួយ នៅទីកន្លែងមួយទៀត ដែលយើងកំពុងទទឹងរង់ចាំទៅ។" ហើយនៅពេលនេះ យើង—យើងចងចាំគ្រប់ទាំងកិច្ច ការនេះ គឺជាបញ្ហាមួយ។

17 នោះហើយ ទើបមនុស្សមួយចំនួនព្យាយាមផ្សព្វផ្សាយ ពីសាសនាគ្រិស្ទថា "អ្នកនឹងមិនមានទុក្ខកង្វល់ទៀតឡើយ។ អ្នក..." ទេ អ្នកមិនទេ។ "អ្នកមិន ជួបបញ្ហាទៀតឡើយ។" អូទេ! អ្នកបានបន្ថែមបញ្ហានៅពេលដែលអ្នកក្លាយជាគ្រីស្ទានព្រោះពីមុនអ្នកជាមនុស្សប្រហែសគ្មានខ្វល់អ្វី គិតតែពីសប្បាយ មិនបាននាំយកនូវអ្វីដែលអ្នកបានប្រព្រឹត្តឡើយ។

18 ប៉ុន្តែនៅពេលដែលអ្នកក្លាយជាគ្រិស្តបរិស័ទ្ធពិតប្រាកដ គ្រប់កិច្ចការទាំងអស់ អ្នកនឹងមានចម្ងល់ "តើខ្ញុំធ្វើគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់របស់ខ្ញុំទេ?" ប្រសិនបើខ្ញុំអាចស្តាប់ឮទ្រង់! វានឹងដាក់អ្នកទៅក្នុងបញ្ហា ដាក់អ្នកទៅក្នុងការការពារ។ នោះហើយ គឺជាអ្វីដែលធ្វើឲ្យអ្នក ជាអ្នកណា។ ហើយសរុបមក បញ្ហាគឺ ជាព្រះពរ។ វាគឺគ្រាន់តែជាផ្លូវដែលអ្នកមើលទៅកាន់វាប៉ុណ្ណោះ។ វាគឺគ្រាន់តែជា របៀបដែលអ្នកមើលទៅកាន់វាប៉ុណ្ណោះ។ ឃើញទេ? ប្រសិនបើអ្នកក្រឡេកមើលទៅ កាន់ផ្នែកមួយផ្សេងទៀត វាគឺ—វាគឺ...មិនថាអ្នកកាត់វាស្តើងប៉ុន្មានោះទេ អ្វីក៏ដោយ អ្នកនឹងទទួលបានពីផ្នែកផ្សេងគ្នាអ្នកឃើញទេ ដូចនេះអ្នកចង់ ឃើញទាំងពីរផ្នែក។

19 ដូច្នេះ បញ្ហា...ខ្ញុំគិតថា "អូ ខ្ញុំអើយ វាជា...តើនេះគឺជាបញ្ហាអ្វី? ប្រសិន បើខ្ញុំកើតមក ដោយមិនមានបញ្ហានេះ។" ល្អ ប្រសិនបើ ខ្ញុំមិនមានបញ្ហានេះ ខ្ញុំនឹង មិនដឹងថាខ្ញុំជាអ្វីឡើយ។ ប្រហែលជាខ្ញុំមិនអាចក្លាយជាគ្រិស្តបរិស័ទ្ធម្នាក់ឡើយ។ គឺជាបញ្ហានេះហើយ ដែលនាំខ្ញុំ ចូលទៅជិតព្រះយេស៊ូគ្រិស្ត។ ឃើញទេ? ដូច្នេះ វាគឺជាព្រះពរមួយសម្រាប់ខ្ញុំ។

20 ដូច្នេះ ក្រោយមក លោកប៉ុលបាននិយាយថា ពេលដែលខ្ញុំមានបញ្ហា ឬក៏មានរឿងអ្វីមួយ ឬក៏អ្វីមួយផ្សេងទៀត គាត់បានអធិស្ឋានទៅកាន់ព្រះជាម្ចាស់ ដើម្បី—ដើម្បីដកយកវាចេញឆ្ងាយពីគាត់អស់រយៈពេលបីដង។ ហើយព្រះជាម្ចាស់មានព្រះបន្ទូលថា "ប៉ូល របស់ខ្ញុំ...ប៉ូលព្រះគុណរបស់យើងបានផ្ដល់មកល្មមគ្រប់គ្រាន់សំរាប់អ្នកហើយ។"

21 គាត់បាននិយាយថា "ក្រោយមក ខ្ញុំនឹងថ្វាយសិរីរុងរឿងនៅក្នុងភាពទន់ខ្សោយរបស់ខ្ញុំ។ បន្ទាប់មក នៅពេលខ្ញុំទន់ខ្សោយ ខ្ញុំនឹងរឹងមាំ។" ឃើញទេ? ដរាបណាវាគឺជាបំណងព្រះហឫទ័យរបស់ព្រះ គ្រប់ការទាំងអស់គឺល្អ។

22 ឥឡូវ ខ្ញុំបានអធិស្ឋានទៅកាន់ទ្រង់នៅពេលមួយ នៅពេលដែលវាធ្លាប់បានរំខានដល់ខ្ញុំខ្លាំង វាបានបំភ័យខ្ញុំ។ ហើយទ្រង់បានមានបន្ទូលមកកាន់ខ្ញុំថា ប្រហែលជា ប្រាំបី ឬក៏ដប់ឆ្នាំកន្លងទៅហើយ ទ្រង់បានមានបន្ទូលថា "ការនេះនឹងមិនធ្វើឲ្យអ្នកភ័យខ្លាចទៀតឡើយ។" ហើយការនេះនឹងមិនកើត មានឡើយម៉ែនទេ។ អត់ទេ លោក កុំ—កុំឲ្យមានការព្រួយបារម្ភអំពីការនេះឡើយ។ ខ្ញុំគ្រាន់តែមានអារម្មណ៍ពីការនេះ ប៉ុន្តែខ្ញុំដឹងថា វាគឺជាការនោះហើយ ប៉ុន្តែខ្ញុំគ្រាន់តែបន្ត ដោយព្រោះវាមិនបានធ្វើឲ្យខ្ញុំភ័យទៀតឡើយ ដូច្នេះហើយ សូមអរព្រះគុណសម្រាប់ការនោះ។

ពេលនេះ ទ្រង់អាចមានបន្ទូលថា "មិនមានការភ័យខ្លាចទៀតឡើយ" ព្រមទាំង "អ្នក នឹងមិន មិនមានភាពភ័យខ្លាចទៀតឡើយ។"

23 ដូច្នេះ វាគឺជាបំណងព្រះហឫទ័យរបស់ទ្រង់ដែលនឹងកើតមានឡើង ដូចនេះហើយខ្ញុំគ្រាន់តែទទួលយក និងនិយាយថា "អរព្រះគុណ ព្រះជាម្ចាស់ ខ្ញុំនឹងជ្រើសរើសយកផ្លូវនោះ។"

24 ឥឡូវ សូមយើងទាំងអស់គ្នាបន្ទាបក្បាលចុះបន្តិច ដើម្បី—ដើម្បីអធិស្ឋាន។ តើមានការស្នើរសុំការអធិស្ឋានជាពិសេសអ្វីទេ? (ខ្ញុំឃើញ កន្លែងដៃគឺដាក់ចុះនៅទីនេះ។) សូមលើកដៃឡើង។ សូមព្រះជាម្ចាស់ ប្រទានពរដល់កូនរបស់អ្នកគ្រប់គ្នា។

25 ឱ ព្រះបិតាដែលគង់នៅឋានសួគ៌អើយ ខណៈពេលដែលយើងចូលខិតជិតព្រះដ៏អស្ចារ្យ បល្ល័ង្កដ៏ខ្ពង់ខ្ពស់បំផុតនៃព្រះគុណ ដោយព្រោះយើងត្រូវបានត្រាស់

ហៅដើម្បីនឹងមកទីនេះ។ យើងមកទីនេះ ដោយបំណងព្រះហឫទ័យរបស់ព្រះយេស៊ូគ្រិស្ត។ ហើយ យើងមកជាមួយនឹងការការពារនិងដេញពួកគេនៅលើទ្រង់ ព្រោះទ្រង់ការពារយើង តើជាការក្សាន្តចិត្តយ៉ាងណា ដោយដឹងថាទ្រង់ការពារយើង។ ព្រះដ៏ធំមហិមានៃឋានសួគ៌ ជាព្រះអាទិករ ថែរក្សាយើង ថែរក្សាការបង្កើតរបស់ទ្រង់។ យើងពិតជា មានអំណរណាស់ព្រះអង្គអើយ។ ជាការកំសាន្តចិត្តដ៏ល្អមួយនៅក្នុងពេលនេះ ដែលយើងមានជីវិតរស់នៅ ដែលវាហាក់បីដូចជា អាច—អាចទាញយកការកំសាន្តចិត្តមិនមែនពីអ្វីឡើយតែជាព្រះបន្ទូលទ្រង់។ នោះជាការលួងលោមយើង គឺជាបន្ទូលសន្យារបស់ទ្រង់។ ហើយ នៅក្នុងបន្ទូលសន្យារបស់ទ្រង់ ទ្រង់បានមានបន្ទូលថា នឹងធ្វើឲ្យការអធិស្ឋានសុំរបស់យើងបានដឹងហើយ "ប្រសិនបើ សុំអ្វីដោយ នៅឈ្មោះខ្ញុំ ខ្ញុំនឹងឲ្យដល់អ្នក" ហើយ ព្រះបន្ទូលសន្យាដ៏អស្ចារ្យទាំងនេះគឺ "ដ្បិតអ្នកណាសុំ អ្នកនោះតែងតែបានទទួល។ សូមនិយាយពាក្យនេះទៅកាន់ភ្នំ 'ចូររើចេញទៅ' ហើយដោយមិនមាន ការសង្ស័យហើយភ្នំនឹងរើចេញ។" ដោយសារព្រះបន្ទូលសន្យាទាំងនេះ ហើយ យើងអាចទទួលយកព្រះបន្ទូលសន្យានោះសម្រាប់អ្វីដែលយើងនឹងអធិស្ឋានសុំ។

26 ដៃបានលើកឡើង ពួកគាត់ត្រូវការអ្វីមួយពីព្រះជាម្ចាស់ ព្រះបិតា អស់អ្នកដែលមានតម្រូវការ សូមប្រទានឲ្យ។ ខ្ញុំសូមថ្វាយការអធិស្ឋានជាមួយនឹងតម្រូវការរបស់ពួកគាត់នៅចំនោះទ្រង់ ដៃរបស់ខ្ញុំលើកឡើងជាមួយពួកគេ។ នៅទីនេះដាក់ដៃចុះនៅលើតុទីនេះ កន្សែងដៃដាក់ចុះនៅទីនេះ។ អូ ព្រះជាម្ចាស់ អ្នកនៅទី នេះពិតជាមានជំនឿ ជំនឿដ៏អស្ចារ្យ...ដូចជាអ្វីមួយដែលទ្រង់ បានប្រទានពរដល់ខ្ញុំដោយអាចអធិស្ឋានសម្រាប់មនុស្សមានជំងឺ។ ទីណាក៏ ដោយ កន្លែងណាក៏ដោយ ទីណាក៏ដោយ ដែលខ្ញុំទៅ គឺជាការមួយអំពីការអធិស្ឋានសម្រាប់អ្នកមានជំងឺ។ ព្រះជាម្ចាស់សូមជួយព្យាបាលឥឡូវនេះ។ ខ្ញុំសូម អធិស្ឋានដោយក្តីស្មោះត្រង់ ដែលទ្រង់នឹងប្រទានឲ្យតាមការអធិស្ឋានពីកន្សែងដៃ ទាំងនេះ ដែលបានដាក់នៅទីនេះ ពីអ្នកដែលបានសំណូមពរអធិស្ឋាន។ សូមឲ្យក្តីមេត្តារបស់ទ្រង់បានដល់ពួកគេ។

27 ព្រះអម្ចាស់ យើងបានដឹងថាបងស្រី ហីគ (Sister Hicks) នាំយកមនុស្សស្រី ម្នាក់នៅទីនេះ ដែលបានមកទីនេះពីទីឆ្ងាយ ដើម្បីទទួលបានការអធិស្ឋានសម្រាប់ ជំងឺមហារីក ហើយចង់ដឹង ថាតើគាត់អាចនាំយកស្ត្រីម្នាក់នេះទៅកាន់

ទីនោះ បានទេ។ ព្រះជាម្ចាស់ ខ្ញុំសូមអធិស្ឋាន ដែលទ្រង់អាចនឹងស្តារជីវិតរបស់ស្ត្រីម្នាក់នោះឡើងវិញ សូមឆ្លើយតបពីការនេះ។ ក្មួយប្រុសតូចរបស់ខ្ញុំ ឈ្មោះ មីគី (Mikie) កំពុងតែដេកជាមួយនឹងជំងឺ និងកំពុងតែក្អួត ជាមួយនឹងកម្តៅដ៏ខ្លាំងគេង ដោយការបើកចំហរទ្វារ។ ឱព្រះអម្ចាស់ ខ្ញុំ—ខ្ញុំជឿ យើងបានអធិស្ឋានដោយជំនឿនៅទីនោះថា ទ្រង់នឹងអាចព្យាបាលជំងឺបាន ហើយខ្ញុំ—ខ្ញុំ—ខ្ញុំសូមថ្វាយការអរគុណទៅកាន់ទ្រង់ មានអារម្មណ៍ថាកម្តៅបានកំពុងតែចេញបាត់ទៅពីក្មេងប្រុសម្នាក់នោះ មុនពេលដែលខ្ញុំបានចាកចេញពីបន្ទប់នេះ។

28 ឥឡូវ ព្រះអម្ចាស់...ហើយអរព្រះគុណទ្រង់សម្រាប់ការទាំងនេះ។ ឥឡូវខ្ញុំបាននិយាយច្រើនពីព្រះបន្ទូលរបស់ព្រះ។ សូមប្រទានព្រះបន្ទូល របស់ទ្រង់មក។ "ព្រះបន្ទូលទ្រង់គឺជាសេចក្តីពិត។" សូមប្រទានពរ ដល់ព្រលឹងរបស់យើង ហើយប្រទានយើងនូវ—ព្រះគុណដែលយើង ត្រូវការដែលយើងនឹង នាំយកវាពីបន្ទូលសន្យារបស់ព្រះជាម្ចាស់នៅយប់នេះ នៅក្នុងព្រះបន្ទូលបានទ្រទ្រង់យើងអស់រយៈមួយសប្តាហ៍នេះ សូមប្រទានការនេះ។ សូមប្រទានពរដល់គ្រូគង្វាលរបស់យើងជាមួយនឹងព្រលឹងដ៏អស្ចារ្យនេះ ប្រទានពរដល់ ប្រពន្ធ កូនៗរបស់គាត់ ជំនួយការគ្រូគង្វាល អ្នកទទួលភារកិច្ចគ្រប់គ្រង និងគ្រប់ មនុស្សទាំងអស់ ដែលចេញ ចូលអាគារនេះ សូមទទួលយកពីព្រះវរបិតា។ យើងសូមអធិស្ឋានសូមព្រះពរទាំងនេះនៅក្នុង ព្រះនាមនៃព្រះយេស៊ូគ្រិស្ត។ អាម៉ែន។

29 ពេលនេះ ខ្ញុំសូមអានពីកន្លែងពីរនៃការសរសេររបស់ព្រះអម្ចាស់។ ខ្ញុំសូមអានពីកណ្ឌគម្ពីរទំនុកតម្កើង ជំពូកទី៨៦។ ហើយបន្ទាប់មកខ្ញុំសូមអានជូនពី ម៉ាថាយ ជំពូទី ១៦ ខ ១ ដល់ខ ៣។ ហើយខ្ញុំសូមអានភាគនៃកណ្ឌទំនុកតម្កើងខ្ញុំមិន អានទាំងអស់ទេ ប៉ុន្តែអានចុះដល់ខទី១១ ដែលពាក់កណ្តាលកណ្ឌនោះបន្តិច។

30 ហើយ ខ្ញុំចង់ប្រកាសពីការនេះ ប្រសិនបើខ្ញុំហៅពីកណ្ឌគម្ពីរ មុនពេលដែលខ្ញុំ អធិប្បាយពីកណ្ឌគម្ពីរនេះ *ពេលវេលានៃការរួបរួម និងទីសម្គាល់*។ "ពេលវេលានៃការរួបរូមនិងទីសម្គាល់" ស្តាប់ទៅដូចជាសាំញ៉ាំបន្តិច។ *ការរួបរួម* (ឃើញទេ?) *ពេលវេលា* ពេលវេលានៃការរួបរួម នោះគឺជាអ្វីហើយនៅពេលនេះ។ ហើយនឹង *ទីសម្គាល់* នៃពេលវេលានៃការរួបរួម។

31 នៅ—នៅក្នុងទំនុកតម្កើង ការអធិស្ឋានរបស់ព្រះបាទដាវីឌ ជំពូកទី៨៦។

*ឱព្រះអម្ចាស់អើយ សូមផ្ទៀងព្រះកាណ៌ចុះស្តាប់ទូលបង្គំ ហើយឆ្លើយតបមកទូលបង្គំវិញផង ដ្បិតទូលបង្គំជាមនុស្សកំសត់ទុគ៌ត។*

*សូមរក្សាការពារជីវិតទូលបង្គំផង ដ្បិតទូលបង្គំមានចិត្តស្មោះត្រង់ចំពោះព្រះអង្គ*

*ឱព្រះនៃទូលបង្គំអើយសូមសង្គ្រោះអ្នកបំរើរបស់ព្រះអង្គដែលបានផ្ញើជីវិត លើព្រះអង្គនេះផង។*

*ឱព្រះអម្ចាស់អើយ សូមប្រណីសន្តោសទូលបង្គំ ដ្បិតទូលបង្គំស្រែកអង្វររកព្រះអង្គពេញមួយថ្ងៃ។*

*សូមប្រោសអ្នកបំរើរបស់ព្រះអង្គអោយមានអំណរសប្បាយព្រះអម្ចាស់អើយ ទូលបង្គំផ្ចង់ចិត្តគំនិតទៅរកព្រះអង្គ*

*ឱព្រះអម្ចាស់អើយ មានតែព្រះអង្គទេ ដែលប្រកបដោយព្រះហឫទ័យសប្បុរស និងចេះអត់អោនអោយយើងខ្ញុំ ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដ៏លើសលប់ ចំពោះអស់អ្នកដែលអង្វររកព្រះអង្គ។*

*ឱព្រះអម្ចាស់អើយ សូមផ្ទៀងព្រះកាណ៌ស្តាប់ពាក្យអធិស្ឋានរបស់ទូលបង្គំ សូមយកព្រះហឫទ័យទុកដាក់នឹងពាក្យទូលអង្វររបស់ទូលបង្គំផង។*

*នៅថ្ងៃមានអាសន្ន ទូលបង្គំអង្វររកព្រះអង្គ ដ្បិតព្រះអង្គឆ្លើយតបមកទូលបង្គំ។*

អូ តើវាមិនអស្ចារ្យទេ? "ទ្រង់នឹងឆ្លើយតបមកទូលបង្គំ។"

*ឱព្រះអម្ចាស់អើយ ក្នុងចំណោមព្រះទាំងឡាយ គ្មានព្រះណាដូចព្រះអង្គទេ ហើយក៏គ្មានព្រះណាអាចធ្វើការអស្ចារ្យ ដូចព្រះអង្គឡើយ។*

*ព្រះអម្ចាស់អើយ ប្រជាជាតិទាំងប៉ុន្មានដែលព្រះអង្គបានបង្កើតមក*

*នឹងនាំគ្នាមកក្រាបថ្វាយបង្គំព្រះអង្គ ហើយលើកតម្កើងសិរីរុងរឿងព្រះនាមព្រះអង្គ។*

*ដ្បិតព្រះអង្គជាព្រះដ៏ឧត្តុង្គឧត្តម ព្រះអង្គធ្វើការអស្ចារ្យ មានតែព្រះអង្គប៉ុណ្ណោះដែលជាព្រះជាម្ចាស់។*

សូមសណ្ដាប់ឥឡូវ។

*ព្រះអម្ចាស់អើយ សូមបង្រៀនទូលបង្គំ អោយស្គាល់មាគ៌ារបស់ព្រះអង្គ ទូលបង្គំនឹង—ទូលបង្គំនឹងប្រព្រឹត្តតាមសេចក្ដីពិតរបស់ព្រះអង្គ សូមប្រទានអោយទូលបង្គំមានចិត្តស្មោះត្រង់ គោរពកោតខ្លាចព្រះនាមព្រះអង្គ។* (ការរួបរួម! ឃើញទេ?)...*សូមប្រទានអោយទូលបង្គំមានចិត្តស្មោះត្រង់ គោរពកោតខ្លាចព្រះនាមព្រះអង្គ។*

32 ខ្ញុំ និយាយពេលនេះអំពី*ការរួបរួម* ហើយនិង*ពេលវេលា ទីសម្គាល់*។ ឥឡូវនេះនៅក្នុងបទគម្ពីរម៉ាថាយជំពូកទី១៦។

*ពួកខាងគណៈផារីស៊ី និងពួកខាងគណៈសាឌូស៊ី នាំគ្នាចូលមក... គាល់ព្រះយេស៊ូ ក្នុងគោលបំណងចាប់កំហុសព្រះអង្គ។ គេសុំអោយព្រះអង្គសំដែងទីសំគាល់មួយបញ្ជាក់ថា ព្រះអង្គបានទទួលអំណាចពីព្រះជាម្ចាស់មក។*

*ហើយ ព្រះអង្គមានព្រះបន្ទូលតបទៅគេថា នៅពេលថ្ងៃលិចកាលណាអ្នករាល់គ្នា ឃើញផ្ទៃមេឃពណ៌ក្រហមអ្នករាល់គ្នាតែងពោលថា ខ្ញុំ...វាជាស្អែកថ្ងៃល្អហើយ។*

*ហើយនៅពេលព្រឹកព្រហាម កាលណាអ្នករាល់គ្នាឃើញផ្ទៃមេឃខ្មៅងងឹត.... អ្នករាល់គ្នាតែងពោលថា ថ្ងៃនេះភ្លៀងហើយ។ អ្នករាល់គ្នាយល់ហេតុការណ៍ផ្សេងៗនៅលើមេឃបាន តែអ្នករាល់គ្នាមិនយល់ទីសំគាល់នាសម័យនេះសោះ?*

ព្រះអម្ចាស់បានបន្ថែមព្រះពរដ៏លើសលប់ទៅកាន់អ្នកដែលអានព្រះ បន្ទូលរបស់ទ្រង់។

33 ឥឡូវ យើងកំពុងតែនិយាយពីការរួបរួម ពេលវេលានៃការរួបរួម ទីសម្គាល់ នៃពេលវេលាការរួបរួម។ ឃើញទេ ព្រះយេស៊ូគង់នៅទីនេះ នៅក្នុងការអាន បទគម្ពីរកាលពីយប់មិញ ទ្រង់បានព្រមានពួកបូជាចារ្យដែលមិនអាចយល់ពីពេល វេលាឬក៏ទីសម្គាល់នៃពេលវេលា។ ពេលនេះ គឺជាពេលវេលាដ៏អស្ចារ្យបំផុត សម្រាប់មនុស្សទាំងអស់ឃើញដែលអាចយល់ពី *ទីសម្គាល់នៃពេលវេលា* ដែលអ្នកកំពុងតែ

*រស់នៅ* ដោយព្រោះព្រះសរសេរពីការនេះយ៉ាងច្បាស់លាស់ ដូច្នេះគ្មាននរណាម្នាក់អាចសម្គាល់ពីការនេះឡើយ។

34 ឥឡូវ ជាធម្មតាខ្ញុំត្រឡប់ទៅវិញ និងដកស្រង់ចេញពីអ្នកដឹកនាំ អ្នកបម្រើរបស់ព្រះអម្ចាស់នៅក្នុងព្រះគម្ពីរ (ដូចជាទីសម្គាល់ ក្នុងសម័យកាលរបស់ណូអេ ទីសម្គាល់នៃសម័យរបស់ដានីយ៉ែលនិង—និងទីសម្គាល់ជា ច្រើនផ្សេងៗទៀត) ប៉ុន្តែខ្ញុំចង់ឆ្លងកាត់មេរៀននោះ នៅយប់នេះ—ដើម្បីសន្សំ ពេលវេលាអាច...ប៉ុន្តែវានៅតែជាវិធីរបស់ព្រះ ដើម្បីផ្តល់ ឲ្យពួកគេ—នូវទីសម្គាល់ធម្មជាតិនៃពេលវេលាមកពីព្រះ ដូច្នេះហើយ គ្រប់គ្នាទាំងអស់នឹងដឹងពីពេលវេលានោះ—នោះគឺជាអ្វី។ ហើយពួកផារាស៊ីទាំងនោះ គួរតែ ដឹងពីពេលវេលារបស់ខ្លួន។ ពួកគេគួរតែដឹងតើពេលនោះគឺជាពេលអ្វី។ ទ្រង់បាន មានបន្ទូលនៅផ្នែកផ្សេងទៀត "បើអ្នករាល់គ្នាស្គាល់ខ្ញុំ អ្នករាល់គ្នាក៏ស្គាល់ពីថ្ងៃ របស់ខ្ញុំដែរ។" ឃើញទេ? វាគឺ—វាគឺជារឿង—ដ៏អស្ចារ្យមួយដែលយើងបានយល់។ ឃើញទេ "គ្មាន យល់ដឹងនោះទេ!"

35 នោះ គឺជាអ្វីដែលតែងតែសំដៅទៅកាន់ព្យាការី ពួកគេបាននិយាយថា "ហើយគាត់មានចំណេះវិជ្ជា ចេះបកស្រាយនិមិត្តហេតុអស្ចារ្យ ពីព្រះអម្ចាស់។ ហើយព្រះបន្ទូលដែលចេញមកពីព្រះអម្ចាស់បានមកពី—មកពីព្យាការីសម័យមុន។" ឃើញទេ ពួកគេមានចំណេះវិជ្ជាតាមរយៈព្រះបន្ទូលរបស់ព្រះអម្ចាស់ ដោយពួកព្យាការី។ ហើយបន្ទាប់មក—ពួកព្យាការីផ្តល់ទីសម្គាល់មួយ។ ដូចជា បុរសម្នាក់បានដេកចំហៀងខ្លួនអស់រយៈពេលជាយូរហើយ បន្ទាប់មកបែរដេក ទៅម្ខាងទៀត។ មនុស្ស ម្នាក់ទៀតត្រូវតែផ្លាស់សម្លៀកបំពាក់ឲ្យគាត់។ ហើយអ្វីមានរឿងជាច្រើនដែលពួក គេបានធ្វើដើម្បីបង្ហាញពីទីសម្គាល់ ដែលពួកគេកំពុងតែរស់នៅ។ ហើយពេលនេះ យើងបានដឹងថាព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដីហើយ—ដូច្នេះ ហើយស្នា ព្រហស្តរបស់ទ្រង់ ទ្រង់អាចពិពណ៌នាពីពេលវេលារបស់ទ្រង់ដោយទីសម្គាល់ របស់ទ្រង់ ជាព្រះដដែលមាន ព្រះជន្មរស់នៅសព្វថ្ងៃ។ ដូច្នេះ យើងត្រូវតែជា អ្វីមួយ...ដូចដែលយើងឃើញពី—ពេលវេលាដែលយើងកំពុងតែរស់នៅ វាត្រូវតែជាអ្វីមួយដែលជាការមើលមិនឃើញ ទីកន្លែងណាមួយ របស់នរណាម្នាក់ ឃើញទេ។ ដោយព្រោះព្រះជាម្ចាស់ នឹងមិនអនុញ្ញាតឲ្យរឿងទាំងនេះកើតឡើងដោយពុំបានផ្តល់ឲ្យយើងនូវ ទីសម្គាល់ ដ៏ជាក់លាក់មួយនោះឡើយ ជាកន្លែង ដែល—ដែលយើងនឹងយល់។

36 ឥឡូវនេះគឺជារឿងបច្ចុប្បន្ន ជារឿងគ្រូគង្វាល យើងមិនបានអានវាទេ ត្រូវទេ។ វាគឺគ្រាន់តែដូចជាអ្វីនៅកាលពីមុន ពួកគេមិនបានគិតថា វាដល់ពេលនោះទេ។ ពួកគេ—ពួកគេបានគិតថា ពួកគេបានកំពុងតែរស់នៅ មានសេចក្តីសុខណាស់ ដូច្នេះហើយ ពួកគេមិនបានទទឹងរង់ចាំព្រះមេស្ស៊ីឡើយ។ ហើយព្រះយេស៊ូបាន មានបន្ទូលថា ការយាងមករបស់ទ្រង់នឹងដូចជា "ប្រៀបបីដូចជាចោរចូលលួច នៅពេលយប់" នៅពេល—នៅពេលមនុស្សមិនបាន ប្រុងប្រយ័ត្នពីការយាងមក របស់ទ្រង់។ ប៉ុន្តែមានស្ត្រីព្រហ្មចារីមួយចំនួនបានជួប ជាមួយទ្រង់ ពាក់កណ្តាល នៃពួកគេ មានប្រេងនៅក្នុងចង្កៀងរបស់ពួកគេ ហើយបានត្រៀមខ្លួនរួចជាស្រេច ពួកគេកំពុងតែរង់ចាំមើលពីទីសម្គាល់នោះ។ ហើយ នោះគឺជាអ្នកដែលខ្ញុំនឹង អធិប្បាយទៅកាន់នៅយប់នេះ ឃើញទេ ទៅកាន់ អស់អ្នកដែលកំពុងតែរង់ចាំ ទីសម្គាល់នៅពេលនេះ ជាទីសម្គាល់នៃការយាងមករបស់ទ្រង់។

37 ទីសម្គាល់ទាំងនេះបានប្រទានមក ដោយព្រះជាអម្ចាស់ គឺផ្តល់ឲ្យតែអ្នកជឿ តែប៉ុណ្ណោះ។ អ្នកដែលមិនជឿមិនដែលឃើញពីទីសម្គាល់នេះឡើយ។ ពួកគេ បាន រំលងហួសពីទីសម្គាល់នេះ ហើយពួកគេមិនបានឃើញទីសម្គាល់នេះទេ។ ហើយ ពេលនេះ គឺជាការប្រាកដដែលទេវតានៃព្រះជាម្ចាស់ អាចឈរជា លើវេទិការ នៅ យប់នេះគឺជាការពិតដូច—ដូចដែលខ្ញុំកំពុងតែក្រឡេកមើលទៅកាន់អ្នក ហើយខ្ញុំអាចក្រឡេកមើលទៅកាន់ទីសម្គាល់នេះ ឬក៏អ្នកអាចមើលពីទីសម្គាល់ នេះ ហើយ ខ្ញុំមិនអាចមើលឃើញវាទេ ឬក៏ខ្ញុំអាចឃើញពីទីសម្គាល់ ហើយអ្នកមិន អាច មើលឃើញវាទេ។ ឥឡូវ អ្នកយល់ពីបទគម្ពីរថា នោះគឺពិតជាសេចក្តីពិត។ ពួកគេបានឃើញ...អ្នកដឹងទេ លោកប៉ូលបានធ្លាក់ចុះ ប៉ុន្តែពួកគេ...គ្មាននរណា ម្នាក់មើលឃើញពន្លឺនោះទេ។

38 ពន្លឺនោះគឺនៅទីនោះ នៅពេលលោកយ៉ូហានបានឈរនៅទីនោះ ចំពោះមុខ មនុស្សដ៏ច្រើន ហើយរាប់ពាន់ចេញពីមាត់ទន្លេនោះ នៃពួកបូជាចារ្យ ហើយ—និង ពួកបណ្ឌិត និង អ្នកអស្ចារ្យជាច្រើន។ ហើយលោកយ៉ូហាន បាននិយាយថា គាត់ ផ្ទាល់ គាត់បានកត់ត្រាពីការឃើញនៃព្រះវិញ្ញាណយាងចុះពីស្ថានសួគ៌ ដូចសត្វ ព្រាបមកសណ្ឋិតលើទ្រង់។ ហើយសម្លេងបានមានបន្ទូលមកថា "នេះជាកូន ស្ងួន ភ្ងាអញ ជាទីពេញចិត្តអញណាស់។" ហើយគ្មាននរណាម្នាក់ ឃើញពីការនេះឡើយ មានតែលោកយ៉ូហានប៉ុណ្ណោះ។ ឃើញទេ? ការនោះគឺសម្រាប់តែគាត់ប៉ុណ្ណោះ។

39 តើអ្នកបានចំណាំថាតើការកើតឡើង នៃទីសម្គាល់សម្រាប់មនុស្សមានប្រាជ្ញាយ៉ាងដូចម្ដេច? ពួកគេបាន...ពួកគេជាជនជាតិហោរ៉ា។ ពួកគេមិនមែន ជាតារាវិទូជនជាតិឥណ្ឌាពិតប្រាកដទេ ពួកគេជាជនជាតិហោរ៉ាពីព្រោះពួកគេមក កាន់ទីនេះ នៅក្នុងប្រទេសនោះសិក្សាអំពីតារាវិជ្ជា ដើម្បីបញ្ចប់ការសិក្សារបស់ពួកគេ។ ហើយនៅពេលពួកគេបាន...មើលទៅកាន់ទីក្រុងយេរូសាឡឹម ហើយ បានដឹងថាពួកគេបានឃើញតារាទាំងបី ពីផ្លូវនីមួយៗ—នៃទីកន្លែងកំណើតរបស់ពួកគេ នៃពូជហាំ សិម និងយ៉ាផែតនៃសាសន៍ដែលពួកគេបានកើតមកនីមួយៗ ហើយពួកគេបានឃើញផ្កាយរបស់ពួកគេ នៅផ្លូវកំណើតរបស់ពួកគេ។ នោះគឺជាទីសម្គាល់គឺនៅពេលដែលផ្កាយនោះស្ថិតនៅតាមបន្ទាត់ ព្រះមេស្ស៊ីគឺចាប់កំណើតនៅលើផែនដី។

40 អូ ខ្ញុំអើយ! មិនថាជាពួកគេមកពីណានោះទេ "តើទ្រង់នៅទីណា?" តើទ្រង់ដែលប្រសូតមកជាស្តេចរបស់ជនជាតិយូដាគង់នៅឯណា? យើងបាន ឃើញតារារបស់ទ្រង់រះនៅទិសខាងកើត ហើយយើងត្រូវតែមកដើម្បីថ្វាបង្គំទ្រង់។ តើទ្រង់គង់នៅទីណា? ពួកគេបានដឹងថាទារកនៃព្រះមេស្ស៊ី គឺកំពុងតែធំនៅទីណាមួយពីព្រោះព្រះជាម្ចាស់បានផ្ដល់នូវទីសម្គាល់នៃពេលវេលាដល់ពួកគេ ជាពេល ដែលព្រះនិងមនុស្សត្រូវបានរួបរួមជាមួយគ្នា។ ជាការរួបរួមដ៏អស្ចារ្យ នៅពេលព្រះ ជាម្ចាស់បានរួបរួមអង្គទ្រង់ នៅក្នុងភាពជារូបរាងមនុស្ស! គោការណ៍នោះ ជាការរួបរួមដ៏អស្ចារ្យបំផុត ដែលមិនធ្លាប់កើតឡើងគឺនៅពេលព្រះរួបរួមជាមួយមនុស្ស ហើយបន្សល់នៅភាពជាព្រះពិតរបស់—ទ្រង់គឺបានចាប់កំណើតជាមនុស្ស និងក្លាយទៅជាមនុស្សម្នាក់ ដូចជាពួកគេដែរ ដើម្បីលោះបាបរបស់ពួកគេ។ ជាការរួបរួម។ តើនោះគឺជាអ្វី? ដែលបាននាំយកមកនូវសន្តិភាព រវាងព្រះជាម្ចាស់ និងមនុស្ស ជារឿងរហូត តើយើងត្រូវអរព្រះគុណយ៉ាង។

41 ហើយទីសម្គាល់មិនបានផ្ដល់ឲ្យ...ឥឡូវសូមគិត គ្រប់មនុស្សទាំងអស់ ហើយនិងតារាសាស្ត្រទាំងអស់ មនុស្សនៅជំនាន់នោះ ម៉ោងរបស់ពួកគេគឺជាផ្កាយ។ មានអ្នកចាំយាមម្នាក់បានឡើង ទៅលើកំពូលខ្ពស់បំផុត—នៃអាគារ ហើយគាត់អាចឈរនៅទីនោះ និងមើលពីពេលវេលា។ ហើយគាត់បានឃើញផ្កាយដ៏ពិតប្រាកដស្ថិតនៅក្នុងកញ្ចុំផ្កាយដ៏ជាក់លាក់ ខណៈពេលដែលពួកគេបានដើរ កាត់ គាត់បានដឹងថាតើពេលនោះគឺម៉ោងប៉ុន្មាន។ អ្នកចាំបានទេនៅក្នុងបទ

គម្ពីរ "អ្នកយាមតើម៉ោងប៉ុន្មានហើយ?" ហើយអ្នកយាមបានមកនិងប្រាប់គាត់ពីម៉ោងប៉ុន្មាននៅពេលនោះ។ ឃើញទេ ពួកគេបានកំណត់ពេលវេលាដោយតារា។

42 ពេលនេះ តើមិនចម្លែកទេឬ ដែលតារាទាំងនេះស្ថិតនៅក្នុងបន្ទាត់សម្រាប់តែមនុស្សបីនាក់ប៉ុណ្ណោះ ហើយគ្មានអ្នកផ្សេងទៀតមើលឃើញវាឡើយ? ឃើញទេ? គឺគ្រាន់តែនៅក្នុងបន្ទាត់ដ៏ជាក់លាក់។ ឥឡូវ អ្នកអាចស្ថិតបែបនោះ ជាបន្ទាត់ជា មួយនឹងបទគម្ពីរ។ ឃើញទេ? នៅពេលតារាទាំងនោះស្ថិតនៅក្នុងភាពរួបរួម ពួកវា បានរួបរួមគ្នាតែមួយជាកញ្ចុំតារា បុរសទាំងបីក៏បានរួបរួមគ្នានៅពេលដូចគ្នាដែរ។ ហើយអ្នកអាចរួបរួមជាមួយព្រះជាម្ចាស់ ដោយព្រះបន្ទូលរបស់ទ្រង់ រហូតទាល់តែ រឿងទាំងអស់នេះក្លាយជាការពិត ហើយអ្នកអាចឃើញពីតារាទាំងនេះនឹងដឹងថា តារាទាំងនោះគឺមានពិតមែន។ ឃើញទេ? ទីសម្គាល់ពេលវេលានៃការរួបរួម! អ្នកអាចក្រឡេកមើលទៅខាងលើបំផុត ដោយនិយាយថា "អា គ្មានប្រយោជន៍!"

43 ប៉ុន្តែសម្រាប់*អ្នក* មិនមែនគ្មានប្រយោជន៍ទេ។ សម្រាប់អ្នក អ្នកបានរួបរួមជាមួយនិងព្រះបន្ទូល ហើយគឺនៅទីនេះ។ បន្ទាប់មកវាពិតជាពន្លឺ ប្អូនប្រុស ផេត (Pat) នៅពេល—ពេល—ពេល—នៅពេលអ្នកឃើញពីទីសម្គាល់នៃការ រួបរួមជាមួយនឹងអ្នកមានជំនឿ។ ហើយនោះគឺជាអ្នកដែលខ្ញុំបានប្រកាសពីការនេះទៅកាន់គឺអ្នកជឿ សម្រាប់អ្នកដែលមិនមានជំនឿមិន អាចឃើញទីសម្គាល់នេះឡើយ។ ហើយតើនោះគឺជាការស្តីបន្ទោសបែបណា ប្រសិនបើ ទ្រង់បានគង់នៅលើផែនដីនាពេលបច្ចុប្បន្ន ទៅកាន់គ្រូគង្វាលទាំងអស់របស់យើង នៅថ្ងៃនេះអ្នកដែលមិនអាចយល់ពីទីសម្គាល់ ទីសម្គាល់ដែលយើងកំពុងតែអាន រាល់ថ្ងៃនៅទីនេះនៅរោងឧបោសថ ហើយកំពុងតែឃើញពីរឿងនេះ។ ហើយអ្នក ផ្សេងទៀតកំពុងតែអានពីការនេះ ហើយកំពុងតែឃើញពីការសរសេរ ដោយដៃនៅលើជញ្ជាំង ហើយអ្នកផ្សេងទៀតបានព្រងើយកន្តើយពីការនេះ ហើយក៏មិនបានឃើញពីការនេះ ទាល់តែសោះ។ វាមិនមានប្រយោជអ្វីសោះដល់ពួកគេ ពួកគេមិនកត់ចំណាំពីការនេះទេ។

44 ឥឡូវ សូមកត់ចំណាំនៅក្នុងនេះថា ទ្រង់—ទ្រង់បានចង្អុលដោយ ទីសម្គាល់ជាតិ។ ពេលនេះនៅពេលដែលពួកគេបានសុំទ្រង់ពីទីសម្គាល់នេះ ពួកចង់បាន ទីសម្គាល់ ទ្រង់នឹងប្រទានទីសម្គាល់ដែលបានកើតឡើងទៅកាន់ពួកគេ។ ហើយ

ពួកគេចង់ដឹងពីទីបញ្ចប់នៃផែនដី តើនឹងមានទីសម្គាល់អ្វីនៅទីបញ្ចប់។ ហើយទ្រង់បានបង្ហាញទីសម្គាល់ដល់ពួកគេជាច្រើនកន្លែងនៅក្នុងបទគម្ពីរអំពីទីសម្គាល់ជាតិ ទីសម្គាល់ស្ថានសួគ៌នៅស្ថានសួគ៌ ទីសម្គាល់ផែនដី ទ្រង់បានឲ្យពួកគេនូវ ទីសម្គាល់ ទីសម្គាល់ ទីសម្គាល់គឺទីសម្គាល់ជាប់ជានិច្ច។ ហើយនៅពេលទ្រង់ ប្រាប់ពួកគេគឺមានកន្លែងមួយអំពី ទីសម្គាល់ ទ្រង់មានបន្ទូលថា "នៅពេលអ្នកឃើញជាតិសាសន៍មួយ" មើល "ចាប់ផ្តើម ប្រមូលផ្តុំនៅជុំវិញទីក្រុងយេរូសាឡឹម" ឃើញទេ បន្ទាប់មក យើងដឹងថាពេល វេលានៃទុក្ខលំបាកជិតមកដល់ហើយ "នៅពេលអ្នកឃើញទីក្រុងយេរូសាឡឹមព័ទ្ធជុំវិញ ដោយសត្រូវ។"

45 ឥឡូវមុនពេលពួកគេអាចធ្វើរឿងនេះ ព្រះជាម្ចាស់...ពិភពលោកត្រូវតែរួបរួមតែមួយ។ លោកទីតុសជាមេទ័ពជនជាតិរ៉ូម៉ាំង ត្រូវតែរួបរួមទ័ពរបស់គាត់តែមួយហើយប្រមូលផ្តុំ បន្ទាប់មកជនជាតិយូដាត្រូវបានបដិសេធទីសម្គាល់នៃពេលវេលាដែល ព្រះជាម្ចាស់ ប្រទានឲ្យពួកគេ។ នោះគឺជាពេលវេលាដែលលោកទីតុសបានរួបរួម កងទ័ពរបស់គាត់តែមួយ ហើយទៅវាយយកទីក្រុងនោះ។ ទីមួយ មានការរួបរួម នៃមនុស្សរបស់ព្រះជាម្ចាស់ (ដែលហៅថា) ប្រឆាំងទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ មុនពេលដែលប្រជាជាតិអាចរួបរួមតែមួយប្រឆាំងទៅនិងមនុស្សរបស់ព្រះជាម្ចាស់។ ឃើញទេ ការ—ការ—ការរួបរួម ការរួបរួមមួយ ការរួបរួម ជាមួយគ្នា។

46 ខ្ញុំជឿថាយើងកំពុងតែរស់នៅក្នុងការរួបរួមដ៏អស្ចារ្យមួយ។ ខ្ញុំបានលើកយកចំណុចពិសេសមកនិយាយ ហើយនិងសញ្ញានៃពន្លឺ ហើយពីគ្រប់កិច្ចការទាំងអស់(ពីរបៀបដែលស្រីធ្វើ នឹងពីរបៀបដែលមនុស្សប្រុសធ្វើ និងពីរបៀបដែលក្រុមជំនុំធ្វើ) ការបង្ហាញទៅកាន់ក្រុមតូចមួយនេះ ដោយអស់ពីចិត្តរបស់ខ្ញុំ ដែលខ្ញុំជឿថាយើងកំពុងតែស្ថិតនៅក្នុងបន្ទាត់នៃព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងពេលនៃការទាយទុកជាមុននេះ គឺគ្រាន់តែមុនពេលការយាងមករបស់ព្រះអម្ចាស់យេស៊ូពេលវេលានៃការរួបរួមតែមួយ ហើយការត្រៀមខ្លួនរួចជាស្រេច។

47 ពេលនេះ អ្នកឃើញទេ មុនពេលលោកទីតុសបានរួបរួមប្រជាជាតិតែមួយ...កងទ័ពរបស់គាត់បានប្រមូលផ្តុំតែមួយ អ៊ីស្រាអែលរួបរួមតែមួយ ហើយរួមជាក្រុម ដោយខ្លួនពួកគេ ដែលពួកគេនិងមិនជឿថាព្រះយេស៊ូជាព្រះមេស្ស៊ីឡើយ។ ពួកគេ បានបដិសេធទ្រង់ ហើយបំបែរទ្រង់ចេញ និងឆ្កាងទ្រង់។ ហើយនៅពេលដែលពួកគេបានបដិសេធសេចក្តីសង្គ្រោះដែលបានប្រទានមកពួកគេ ពួកគេបាន

រួបរួម តែមួយដើម្បីធ្វើរឿងបែបនោះ។ ឥឡូវ សូមចាំវានៅក្នុងចិត្តរបស់អ្នក ការរួបរួមខ្លួនរបស់ពួកគេតែមួយ ដើម្បីបដិសេធព្រះបន្ទូលនៃពេលវេលា! ពួកគេត្រូវតែធ្វើបែបនោះ។ ហើយ ក្រោយមកនៅពេលពួកគេបានធ្វើបែបនោះ បន្ទាប់មកទីសម្គាល់និងមកដល់។

48 ប្រជាជាតិចាប់ផ្តើមរួបរួមគ្នាតែមួយ ហើយលោកទីតុស បាននាំកងទ័ពដ៏ អស្ចារ្យនេះរបស់រ៉ូម៉ាំងហើយនិងក្រិចហើយហ៊ុំព័ទ្ធកំពែងទីក្រុងយេរ៉ូសាឡឹម ប្រមូលផ្តុំមនុស្សនៅទីនោះនាពេលនេះ ហើយពួកគេបានអត់បាយស្លាប់។ ពួកគេបរិ ភោគតែសំបកឈើពីដើមឈើ។ យ៉ូសេហ្វឹសជាប្រវត្តិវិទូដ៏អស្ចារ្យម្នាក់បានប្រាប់ យើង។ ហើយពួកគេបរិភោគស្មៅពីដី។ ពួកគេក៏ធ្លាប់ស្ងោកូនៗរបស់អ្នកដទៃហើយបរិភោគ ឃើញទេពួកគេដូចជាមនុស្សឆ្កួត។ ហើយក្រោយមក នៅទីបញ្ចប់ លោកទីតុស កំពុងតែអង្គុយនៅក្រោយភ្នំ នៅក្បែរទីក្រុងយេរ៉ូសាឡឹម ហើយ—ហើយមនុស្សនៅទីនោះ បានគិតថាពួកគេកំពុងតែធ្វើរឿង តាមព្រះហឬទ័យរបស់ព្រះ នៅពេលពួកគេបានឃើញសត្រូវអស់ទាំងនេះ កំពុងតែដើរជាក្បួន។ ពួកគេបានបដិសេធពីការលើដែលចៅហ្វាយដ៏អស្ចារ្យ គឺព្រះអម្ចាស់យេស៊ូ ប្រាប់ពួកគេ ពីការនោះ។

49 ទីនោះមិនមានគ្រីស្ទបរិស័ទ្ធ ណាម្នាក់ទៅទីនោះឡើយ ដោយពួកគេបានឃើញពីទីសម្គាល់ ហើយបានចាកចេញទៅ។ ឃើញទេ? ពួកគេបាននិយាយថា "រីឯអ្នកនៅលើដំបូលផ្ទះ មិនត្រូវចុះមកយកអ្វីៗនៅក្នុងផ្ទះឡើយ ហើយអ្នកដែលនៅឯចំការ ក៏មិនត្រូវវិលទៅផ្ទះយកអាវធំរបស់ខ្លួនដែរ ចូរទូលអង្វរព្រះជាម្ចាស់ សូមកុំអោយអ្នករាល់គ្នាត្រូវរត់ភៀសខ្លួននៅរដូវត្រជាក់ ឬនៅថ្ងៃសប្ប័ទ។" ពីព្រោះ នៅរដូវរងារ ភ្នំ—ភ្នំនិងពោរពេញទៅដោយព្រិល ហើយនៅថ្ងៃសប្ប័ទ ទ្វារ—ទ្វារ ទាំងអស់ត្រូវបានបិទ ច្រកក៏បិទ ហើយពួកគេនិងត្រូវស្ថិតនៅក្នុងស្ថានភាពបែប នោះ។ ឃើញទេ? យើងចង់ឲ្យថ្ងៃនោះបានមកដល់ឆាប់អំពី...របៀបដែលព្រះជា ម្ចាស់ធ្វើកិច្ចការអស់ទាំងនោះ ប្រសិនបើជាបំណងព្រះហឬទ័យរបស់ព្រះជា ជាអម្ចាស់។

50 សូមកត់ចំណាំឥឡូវទ្រង់...ពួកគេអធិស្ឋានថាវាអាចបែបនោះ...មិនកើតឡើងបែបនោះឡើយ ព្រះយេស៊ូមានបន្ទូលប្រាប់ពួកគេឲ្យអធិស្ឋានសម្រាប់ការនោះ ហើយពួកគេមិនបានចាប់នរណាម្នាក់ នៅក្នុងចំណោមពួកគេនៅទីនោះ

ឡើយ។ ពួកគេបានចាកចេញទៅដោយព្រោះពួកគេបានមើលទៅកាន់ទីសម្គាល់ ហើយពួកគេបានចាកចេញទៅ នោះហើយគឺជាអ្វីកើតឡើងនៅទីនោះ។

51 អូ តើក្រុមជំនុំសព្វថ្ងៃគួរតែឃើញពីទីសម្គាល់នៃពេលវេលាដែលយើងកំពុងតែរស់នៅដោយរបៀបណា! រត់គៀសខ្លួនតាមតែអ្នកអាចធ្វើ បានទៅកាន់កាល់វ៉ារី ឲ្យរួចជីវិត មិនមែនទៅកាន់ព្រះវិហារនោះទេ ប៉ុន្តែទៅកាន់ព្រះយេស៊ូគ្រិស្ត។ រួបរួមខ្លួនរបស់អ្នកជាមួយទ្រង់ ហើយមិនត្រូវរួបរួមជាមួយនិងអង្គការ ឬក៏លទ្ធិ គោលជំនឿរបស់ក្រុមជំនុំណាឡើយ។ រួបរួមជាមួយព្រះគ្រិស្ត ហើយត្រូវប្រាកដ ថានោះគឺជាទ្រង់ អ្នកមិនអាចយកអ្វីទៅបានទាំងអស់ឡើយ អ្នកត្រូវតែមនុស្ស មានគំនិតវិជ្ជមានថានោះគឺជាទ្រង់។ ជាពេលវេលានៃការរួបរួមដ៏អស្ចារ្យ!

52 ឥឡូវយើងបានដឹងថាពួកគេបានបដិសេធព្រះមេស្ស៊ី ក្រោយមក ពួកគេបាន រួបរួមតែមួយដោយខ្លួនរបស់ពួកគេ ហើយបានទាញពួកគេបង្កើតជាសម្ព័ន្ធមួយ ហើយបង្កើត—ជា...ចលនាមួយក្នុងចំណោមពួកគេ ប្រសិនបើនរណាម្នាក់បានទទួលជឿលើព្រះយេស៊ូជាព្យាការីនោះ ពួកគេនឹងបណ្តេញចេញពីក្រុមជំនុំ។ អ្នកចាំបានទេពីក្មេងប្រុសដែលពិការភ្នែកដែលបានអង្គុយទាំងភ្នែកខ្វាក់? ហើយពួកសិស្សបាននិយាយថា"តើមកពីបាបរបស់នរណា? បាបរបស់គាត់ផ្ទាល់ ឬបាប របស់ឪពុកម្តាយគាត់?"

53 ព្រះយេស៊ូមានព្រះបន្ទូលតបថា "នៅក្នុងករណីនេះ គាត់ខ្វាក់ មិនមែនមកពីបាបរបស់ឪពុកម្តាយគាត់ ឬបាបរបស់គាត់ទេ គាត់ខ្វាក់ដូច្នេះ ដើម្បីអោយព្រះជាម្ចាស់បង្ហាញកិច្ចការរបស់ព្រះអង្គនៅក្នុងគាត់។"

54 ហើយតើអ្នកចាំទេថា ពួកគេបាននិយាយឪពុកនិងម្តាយរបស់ក្មេងនោះមិនអាចនិយាយពីការនេះបានឡើយ។ ពួកគេបាននិយាយថា "ពួកគេបានស្គាល់ថា នេះគឺជាកូនប្រុសរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងថាគាត់ត្រូវបានជាសះស្បើយដោយរបៀប ណាឡើយ។" ដោយព្រោះថាជនជាតិយូដាណាក៏ដោយដែលសារភាពថាទ្រង់គឺជាព្យាការី នោះពួកគេនិងត្រូវផ្តាច់ចេញពីក្រុមជំនុំ។

55 ប៉ុន្តែ អ្នកឃើញទេ កិច្ចការរបស់ព្រះជាម្ចាស់ក្មេងប្រុសម្នាក់មិនមែនជាកម្មសិទ្ធិរបស់ក្រុមនោះឡើយ។ ហើយទ្រង់មានបន្ទូលថា "ឥឡូវ វាគឺជារឿងចម្លែកសម្រាប់ខ្ញុំ អ្នកមិនបានស្គាល់ពីកន្លែងដែលបុរសនោះមកពីណា ប៉ុន្តែគាត់បានធ្វើឲ្យភ្នែករបស់ខ្ញុំភ្លឺ។" ឃើញទេ? ពេលនេះគាត់អាចនិយាយពីការនេះ។ ឃើញ

ទេ នោះគឺជាកិច្ចការរបស់ព្រះជាម្ចាស់។ ទ្រង់បានព្យាបាលយ៉ាងអស្ចារ្យ ហើយគាត់—អាចប្រាប់ពីការនេះ ដោយព្រោះគាត់មិនមានចំណងចងគាត់កន្លែងណាឡើយ។ ទ្រង់តែមួយគត់ដែលធ្វើកិច្ចការនោះបានសម្រេច ហើយគាត់ពិតជាបានឃើញទ្រង់ពិតប្រាកដ...ជាលើកទីមួយសម្រាប់ជីវិតរបស់គាត់។

56 ឥឡូវយូដាបានរួបរួមខ្លួនរបស់ពួកគេ ហើយប្រឆាំងនិងព្រះយេស៊ូ និង—និងភាពជាព្រះមេស្ស៊ីរបស់ទ្រង់ ហើយនិងរាជសាររបស់ព្រះមេស្ស៊ី។ យើងឃើញដូចគ្នា ឥឡូវបានកើតឡើងនាពេលនេះ គឺរឿងដូចគ្នា។ លទ្ធិកុម្មុយនីស្តគឺកំពុងតែរួបរួមដើម្បីបំផ្លាញក្រុមជំនុំហើយគឺជាផ្លូវតែមួយដែល...ដែលមានបន្ទាប់ពីក្រុមជំនុំត្រូវបានរួបរួមដែរ ជាក្រុមប្រឹក្សានៃក្រុមជំនុំ ក្រុមប្រឹក្សាពិភពលោកនៃក្រុមជំនុំដើម្បីបដិសេធ ហើយនិង ដើម្បីបំផ្លាញព្រះរាជសារ ព្រះបន្ទូល! ពួកគេបានធ្វើឲ្យព្រះបន្ទូលដែលក្រុមជំនុំមានធ្លាក់ចុះ! ពួកគេមិនអាចទទួលយកវាបានទេ ពីព្រោះវាប្រឆាំងទៅនឹងគោល លទ្ធិនៃនិកាយរបស់ពួកគេ មិនថាមានដុំភ្លើងប៉ុន្មានព្យួរ—នៅក្នុង ចំណោមមនុស្សយ៉ាងណា ឬក៏មានមនុស្សច្រើន...និងមានរឿងច្រើនប៉ុណ្ណាដែលព្យាករណ៍ ហើយនឹងកើតឡើងយ៉ាងណា ហើយគ្រប់ទីសម្គាល់ដ៏អស្ចារ្យប៉ុណា ទ្រង់បានសន្យានៅថ្ងៃចុងបញ្ចប់ ពួកគេមិនទទួលយកឡើយ។

57 ដូច្នេះហើយ ពួកគេកំពុងតែរួបរួមខ្លួនឯងឥឡូវ ហើយគ្រូគង្វាលរបស់អ្នកនៅទី នេះ ហើយនិងមនុស្សជាច្រើនអាចប្រាប់អ្នក ពីការអាននោះ ថាពួកគេគឺ...មានចលនានៃក្រុមគ្រិស្ទានច្រើនក្រុមនៃ—នៃ—នៃពិភពលោក។ ហើយ...មានអ្នកដឹកនាំលូធើរៀនគ្រប់គ្រងលើវា។ ការនោះប្រសិនបើមានការបំផ្លាញមួយកើតឡើងនៅក្នុងភាពជាអ្នកជិតខាងនៅទីនេះ ប្រសិនបើយើងមិនបានរួប រួមជាមួយនិងចលនានៃគ្រិស្តសាសនាទាំងនោះ បន្ទាប់មកព្រះវិហាររបស់យើង លែងក្លាយជាព្រះវិហារទៀតហើយ ហើយពួកគេអាចយកព្រះវិហារធ្វើជាឃ្លាំង។ ឬក៏ប្រសិនបើបងប្អូនក្នុងចំណោមពួកយើង ឃើញនរណាម្នាក់ជិតស្លាប់ ឬក៏ឈឺហើយព្យាយាមគ្រប់គ្រងគាត់ប្រទានពរដោយវិញ្ញាណផ្សេងៗ យើងអាចចាប់យកវាបានប្រាកដណាស់។ យើងអាច ត្រូវជាប់ពន្ធនាគារដប់ឆ្នាំសម្រាប់ការធ្វើជាអ្នកដឹកនាំក្រៅប្រព័ន្ធពីព្រោះតែយើងមិនមែនជាសមាជិកនៃចលនាគ្រិស្តសាសនាទាំងនោះ។ តើអ្នកមិនឃើញពីសញ្ញានៃសត្វនោះឬទេ? ឃើញទេ? ឃើញទេ?

58 ឥឡូវយើងឃើញពីពេលវេលានៃការរួបរួមកំពុងតែមកដល់។ ឃើញទេ? ឥឡូវ

សូមមើល! ហើយក្រោយមកក្រុមជំនុំត្រូវបានរួបរួមខ្លួនឯងប្រឆាំងទៅនិងរាជសារ បន្ទាប់មក នៅពេលរឿងនោះកើតឡើង ប្រជាជាតិកំពុងតែរួបរួមខ្លួនឯងជាមួយលទ្ធិកុម្មុនីស្តដើម្បីបំផ្លាញក្រុមជំនុំម្តងទៀត ជាការពិតនូវអ្វីដែលបានកើតឡើងជាលើកទីមួយ។ ឃើញទេ? វាកើតឡើងវិញម្តងទៀតដោយខ្លួនវាផ្ទាល់។

59 អ៊ីស្រាអែលត្រូវតែធ្វើឲ្យព្រះបន្ទូលធ្លាក់ចុះជាមុនសិន។ ហើយនៅពេលពួកគេបានធ្វើឲ្យព្រះបន្ទូលធ្លាក់ចុះ ក្រោយមក កងទ័ព ជីវិតរបស់ប្រជាជាតិត្រូវបានរួបរួមតែមួយដោយខ្លួនវាផ្ទាល់ (នៃប្រជាជាតិផ្សេង) ហើយចូលមកបំផ្លាញក្រុមជំនុំ។ ហើយបច្ចុប្បន្ន ពួកគេបានធ្វើឲ្យព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូធ្លាក់ចុះ ហើយពួកគេបានធ្វើឲ្យព្រះបន្ទូលធ្លាក់ចុះ។ ហើយពេលនេះ ពេលវេលាគឺបានមកដល់កន្លែងដែលលទ្ធិកុម្មុនីស្តកំពុងតែរួបរួមពិភពលោកជាមួយគ្នាប្រឆាំងទៅនិងក្រុមជំនុំ។ ឃើញទេវាត្រូវតែ កើតឡើងតាមបែបនោះ។ ឥឡូវវាពិបាកក្នុងការនិយាយបែបនោះ។

60 វាពិបាកសម្រាប់ជនជាតិយូដាដើម្បីជឿ ពួកគេបាននិយាយថា "បងប្អូនអើយ យើងឃើញ—ថាយើង—ព្រះរបស់យើងគឺគង់នៅជាមួយយើង ហើយយើងនិង—យើងនិងចូលទៅក្នុងព្រះវិហារ។ ហើយពេលនេះយើងនិង អធិស្ឋាន ហើយសូមយាងព្រះវបិតាដ៏បរិសុទ្ធ *គឺចឹង–និង–ចឹង* ហើយព្រះវបិតាដ៏បរិសុទ្ធ *គឺចឹង–និង–ចឹង* ដឹកនាំក្នុងការអធិស្ឋាន។ សូមបិទទ្វារ!" ហើយលោកទីតុស បានឈរ ហើយបានឈរនៅទីនេះអស់រយៈពេលប្រហែលជាមួយឆ្នាំ ឬក៏ច្រើន ជាងនេះ។ ឃើញទេ នៅឃាម ហើយបង្អត់អាហារដល់ពួកគេ។ មិនមាននរណាម្នាក់ធ្លាប់បានចេញពីទីក្រុងឡើយ ហើយពួកគេបានស្លាប់ ដោយអត់អាហារ។ ហើយនៅពេលពួកគេបានចូលទៅទីនោះ ហើយបានបំបែកកំពែង ឈាមបានបាញ់ចេញមក ហើយហូរចុះដូចជាទឹកទន្លេនៅទីនោះ ជាកន្លែងដែល មានការសម្លាប់រង្គាលគ្រប់អ្វីៗទាំងអស់នៅទីនោះ។

61 ឥឡូវទេវតានៃព្រះអម្ចាស់បានទាយពីការនោះត្រឡប់ទៅកាន់បទគម្ពីរសញ្ញាចាស់ ហើយបានប្រាប់ថាការនោះនឹងកើតឡើង។ ហើយពួកបេសកជនដែលជាគ្រូគង្វាល គឺជាអ្នកដែលត្រូវបានតែងតាំង និងដើម្បីប្រាប់មនុស្សពីការនោះ ជំនួសឲ្យការនោះ នៅពេលព្រះយេស៊ូបានយាងឈរនៅក្នុងចំណោមពួកគេ ពួកគេមិនទាំងស្គាល់ទ្រង់ផង ហើយព្យាយាមធ្វើអ្វី មួយ—មួយ...ប្រភេទនៃ

—របស់នាំសំណាង "សូមធ្វើអ្វីមួយឲ្យយើង ឲ្យយើងឃើញពីរបៀប—ដែលកិច្ចការនោះ បានសម្រេច! បង្ហាញយើងនូវទីសម្គាល់។" ឃើញទេ?

ហើយទ្រង់មានបន្ទូលថា "ខ្ញុំ..." ហេតុអ្វី ទ្រង់បាន សម្រេចកិច្ចការជាច្រើន ប៉ុន្តែពួកគេមិនបានឃើញវាទេ។ ឃើញទេ? ក្រោយមកនៅពេលពួកគេបដិសេធទ្រង់ដែលជារាជសារ...របស់ពួកគេនៃថ្ងៃនោះ ពួកគេបានបដិសេធព្រះ បន្ទូលនៅថ្ងៃនោះ។

62 ពួកគេបរាជ័យក្នុងការមើលឃើញពីទីសម្គាល់នៅថ្ងៃនោះ។ ហើយទីសម្គាល់នៃ—នៃទំនាយរបស់ព្រះគម្ពីរត្រូវបានធ្វើឡើងមុនពួកគេ ហើយពួកគេបាន និយាយថា "សូមយើងចូលទៅខាងក្នុង!" ពួកគេគឺជាមនុស្សបរិសុទ្ធ។ ពួកគេគឺជា មនុស្សគ្មានកំហុស មិនអាចចោទប្រកាន់ពួកគេដោយប្រការណាមួយឡើយ។ ពួកគេមិន អាចគ្មានកំហុស*នោះ*ទេ ហើយក្រោយមក—ហើយក្រោយមកជាម្នាក់—ម្នាក់—បូជាចារ្យម្នាក់។ បូជាចារ្យនិងត្រូវបានគេសម្លាប់ គាត់និងត្រូវគេចោលនិងដុំថ្មឲ្យ ស្លាប់សម្រាប់ការអាក្រក់តូចមួយដែលគាត់បានធ្វើ។ ដូច្នេះគាត់ត្រូវតែរស់នៅដោយភាពស្អាត ជាជីវិតដ៏បរិសុទ្ធ។ គាត់មិនអាចធ្វើសង្ស័យទេ ពីព្រោះគាត់ត្រូវបានគេចោលនិងដុំ ថ្មសម្រាប់រឿងដ៏តូចតាចមួយ។ ហើយឥឡូវពួកគេគឺជាមនុស្សដ៏អស្ចារ្យ និងជា មនុស្សបរិសុទ្ធនៅក្នុងភ្នែករបស់មនុស្ស ប៉ុន្តែពួកគេបានដើរចូល ហើយនិយាយថា "ឥឡូវយើងនិង...យើងមានព្រះជាម្ចាស់ ព្រះជាម្ចាស់ដែលគង់នៅ ជាមួយយើង អស់រយៈពេលជាយូរមកហើយ។ យើងនិងចូលទៅក្នុងព្រះវិហារ ដ៏បរិសុទ្ធរបស់ទ្រង់" នោះគឺជាព្រះវិហារដ៏បរិសុទ្ធរបស់ព្រះជាម្ចាស់! ប៉ុន្តែ អ្នកឃើញទេ ទ្រង់បាន ធ្វើឲ្យព្រះវិហារធ្លាក់ចុះនៅក្នុងព្រះវិហារដ៏បរិសុទ្ធរបស់ទ្រង់។ ឃើញទេ? "យើងនិងចូលទៅក្នុងដំណាក់នៃព្រះអម្ចាស់។ ពេលនេះយើងទាំងអស់គ្នា ជាជនជាតិហេព្រើដឹងថាយើងជាជាតិសាសន៍ ដែលព្រះបានជ្រើសរើស យើងគឺនៅទីនេះ ហើយព្រះជាម្ចាស់គឺជាព្រះរបស់យើង ជាព្រះនៃលោកអ័ប្រាហាំ អ៊ីសាក ហើយនិងយ៉ាកុប។ ទ្រង់គឺគង់នៅជាមួយយើង។ ទ្រង់និងជួយយើងចេញពីពួកមិនកាត់ស្បែក ពួកភីលីស្ទីន (ដូចពីមុន) ពួកគេជាជនជាតិរ៉ូម និងគ្រិច។ ទ្រង់បញ្ជូនយើងចេញពីទីនោះ។ សូមយើងចូលទៅក្នុងដំណាក់នៃព្រះ អម្ចាស់!"

63 ការនោះ ស្តាប់ទៅដូចជាល្អ ប៉ុន្តែតើពួកគេបានធ្វើរឿងអ្វីខ្លះ? អ្នកសាងសង់ព្រះដំណាក់គឺនៅទីនេះ ជាទម្រង់នៃជាងឈើអ្នកស្រុកកាលីឡេ ហើយពួកគេបានធ្វើឲ្យទ្រង់ធ្លាក់ចុះ នៅពេលព្រះបង្ហាញសេចក្តីពិតនៃអ្នកនាំសាររបស់ទ្រង់នៃពេលវេលា និងមែក។ ហើយពួកគេបានធ្វើឲ្យ វាធ្លាក់ចុះ។ ដូច្នេះការអធិស្ឋានទាំងអស់ ភាពស្មោះត្រង់ទាំងអស់ គ្រប់ទាំងយញ្ញ បូជាទាំងអស់របស់ពួកគេមិនមានប្រ យោជន៍អ្វីទាល់តែសោះដល់ព្រះជាម្ចាស់។ ពួកគេបានសម្រេចវា! ហើយព្រះជាម្ចាស់អនុញ្ញាតឲ្យទាហានដ៏ អស្ចារ្យនោះ រួបរួមគ្នាដើម្បីបំផ្លាញវា។

64 ហើយយើងឃើញនៅសព្វថ្ងៃនេះ ដូចជាក្រុមជំនុំ ជាច្រើនតាមរយៈនិកាយ ហើយអ្វីទៀតកំពុងតែធ្វើឲ្យព្រះបន្ទូលនៃព្រះជាម្ចាស់ធ្លាក់ចុះ។ ពួកគេមិនត្រូវ ការឲ្យអ្នកប្រាប់ពួកគេពីរឿងអស់ទាំងនេះទេ ហើយវិទ្យាសាស្ត្រអាច បញ្ជាក់ពីការ នេះដោយរូបភាព និងអ្វីៗផ្សេងទៀត ហើយពួកគេនៅតែមិនចង់ធ្វើអ្វីទាំងអស់ ជាមួយនិងការនេះឡើយ។ ដូច្នេះលទ្ធិកុម្មុនីស្តគឺបង្កើតឡើងដើម្បីតែបំផ្លាញវា ពិតដូចជាអ្វីដែលលោកទីតុសបានធ្វើ ហើយនៅក្នុងបទគម្ពីរបានចែងថា ពួកគេនិងធ្វើការនេះ។ ពិតណាស់!

65 ឥឡូវ អ្នកឃើញពីកន្លែងដែលយើងកំពុងរស់នៅ? ជាពេលវេលានៃការរួបរួម។ នៅពេលយើងឃើញការទាំងនេះត្រូវបានរួបរួម អូ ហេតុអ្វី យើងមិនបានឃើញពីការទាំងនោះឡើយ! អ្នកអាច—អ្នកអាចមើលនៅទីនេះ នៅក្នុងបទគម្ពីរ ហើយឃើញកន្លែងដែលទ្រង់បានសន្យា ពីអ្វីដែលទ្រង់និងត្រូវធ្វើ យើងឃើញការនេះកំពុងត្រឡប់ទៅកាន់អតីតកាល។ យើងឃើញប្រជាជាតិរួបរួមគ្នា។ យើងឃើញទ្រឹស្តីកំពុងតែរួបរួមគ្នា។ យើងឃើញក្រុមជំនុំកំពុងរួបរួមគ្នា។ នេះគឺជាពេល វេលានៃការរួបរួម។ វាគឺជាពេលវេលានៃការរួបរួម។ នោះគឺជាពេលនៃព្រះវិញ្ញាណ "យើងត្រូវតែរួបរួម។" គ្រប់ការដែលអ្នកនិយាយទាំងអស់ត្រូវតែរៀបចំទោះបី រដ្ឋាភិបាលមិនទទួលយកក៏ដោយ។

66 អ្នកដឹងទេ ជាពលរដ្ឋម្នាក់...ខ្ញុំមិនអាចទេ ជាពលរដ្ឋ ពលរដ្ឋអាមេរិចម្នាក់ បើខ្ញុំ—ខ្ញុំ...អ្នកអាចឲ្យសែកខ្ញុំប្រាំដុល្លា ប៉ុន្តែ ខ្ញុំមិនហ៊ានដាក់ឈ្មោះរបស់ខ្ញុំនៅលើលុយនោះឡើយ។ ឃើញទេ? ឃើញទេ ខ្ញុំមិនអាចធ្វើវាបានទេ។ ឃើញទេ វាគឺជាពេលវេលានៃការរួបរួម។ គ្រប់ការទាំង អស់ត្រូវតែទៅតាមរយៈការរួបរួមគ្នានៃប្រភេទបែបនេះ ហើយការរួបរួមនោះ គឺជា រឿងតែមួយដែលនាំមកនូវសញ្ញារបស់

សត្វ។ ឃើញទេ? វាគឺជាពេលវេលានៃការ រួបរួម ហើយវា កំពុងតែដំណើរការយ៉ាងត្រឹមត្រូវទៅកាន់ការនោះ។ អ្នកអាចឃើញ ការនេះ ជាមួយ និងភ្នែកផតរៀចវេររបស់អ្នក ប្រសិនបើអ្នកក្រឡេកមើលទៅ កាន់ការនេះ។ វាគឺជា ពេលវេលានៃការរួបរួមជាកន្លែងដែលគ្រប់អ្វីៗទាំងអស់ គឺកំពុងតែរួបរួមគ្នា។

67 ជនជាតិយូដា—ជនជាតិយូដាបានរួបរួមគ្នា ប្រឆាំងនឹងព្រះយេស៊ូដែលជា—ព្រះមេស្ស៊ីរបស់ពួកគេ។ ដូច្នេះហើយ យើងឃើញពីអ្វីដែលបានកើត ឡើង។ យើងឃើញរឿងដូចគ្នានាពេលនេះលទ្ធិកុម្មុនីស្តកំពុងរួបរួមដើម្បីបំផ្លាញ ក្រុមជំនុំបន្ទាប់ពីក្រុមជំនុំត្រូវបានរួបរួមតែមួយនៅ ក្នុងក្រុមប្រឹក្សាក្រុមជំនុំពិភពលោក ហើយ ព្យាយាមបំផ្លាញសារព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ពួកគេព្យាយាម បំផ្លាញព្រះបន្ទូលចោល។ រឿងតែមួយដែលពួកគេអាចធ្វើបានគឺទាញខ្លួនគេទៅក្នុងក្រុមប្រឹក្សាព្រោះតែពួកគេបានញែកពីគ្នា ជាក្រុមតូចៗដូចជា ពួកមេតូឌីស ពួកបាទីស្ត ពួកលូធើរៀន និងព្រីសប៊ីធីរៀន ក្រុមជំនុំនៃព្រះគ្រិស្ត ជាដើមបែបនោះ។ ពួកគេមិនអាច ធ្វើអ្វីបានទាំងអស់ ដោយព្រោះ មួយ*នេះ*និង ប្រឆាំងមួយ*នេះ* ហើយមួយ*នេះ*និង ប្រឆាំងនិងមួយ*ផ្សេងទៀត* គោលិទ្ធិរបស់ពួកគេគឺខុសគ្នាដូជខាងកើតទៅ ខាងលិចអ៊ីចឹង។ ឃើញទេ ពួកគេមិនអាចធ្វើ ការនេះបានទេ។ ប៉ុន្តែពេលរួមគ្នា តែមួយ ស្ថិតនៅក្រោមការគ្រប់គ្រងដ៏ធំមួយ ពួកគេអាចធ្វើវាបាន។ ក្រោយមកពួក គេអាច ធ្វើវាបាន។

68 នោះហើយគឺជាវិធីដែលពួកកាតូលិករួបរួមគ្នាយ៉ាងខ្លាំង រ៉ូម៉ាំងកាតូលិកជា មូលហេតុធ្វើឲ្យពួកគេរួបរួមគ្នាពួកគេ...ភាគច្រើនជារ៉ូម៉ាំងកាតូលិក ពួកក្រិចហើយនិងពួកកាតូលិកផ្សេងទៀត គឺ—គឺ មិនមានចំនួនច្រើនដូចជាពួករ៉ូម៉ាំងកាតូលិកឡើយ។ ពេលនេះពួកគេរួបរួមតែមួយ ហើយនោះហើយគឺជាមូលហេតុដែលពួកគេឈរជាមួយគ្នា។ មិនថាមានរឿងអ្វីកើតឡើងសម្តេចផប់គឺជាអ្នកដឹកនាំគ្រប់អ្វីៗទាំងអស់។ ឃើញទេ? ហើយមិនថាអ្នកណា និយាយអ្វីនោះទេ "ទ្រង់គឺជាអង្គដែលមិនចេះភាន់ច្រឡំ ទ្រង់ជា—ទ្រង់ជា—ទ្រង់ជាជំនួយការរបស់ព្រះជាម្ចាស់គឺបែបនោះហើយ ទ្រង់គង់នៅជិតព្រះជាម្ចាស់ ទ្រង់មានអំណាចលើឋានឃុំព្រលឹង ឋានសួគ៌ និងឋាននរក។" ឃើញទេ? ដូច្នេះ មិនមានកិច្ចការណាដែលធ្វើមិនបានឡើយក្នុងករណី *នោះ* អ្វីក៏ដោយដែលទ្រង់មានបន្ទូល នោះគឺទ្រង់ត្រូវតែធ្វើ។

69 ឥឡូវប្រូតេស្តង់ គឺកំពុងតែធ្វើឲ្យខ្លួនរបស់ពួកគេក្លាយ ជាអ្នកដឹងនាំបែបដូច នោះដែរ គឺដូចគ្នា។ ហើយតើបទគម្ពីរមិនបានមានចែងថាមានរូបភាពធ្វើឡើង តាមទីសម្គាល់របស់សត្វទេឬ? តើនោះគឺជារូបភាពអ្វី? វាគឺជាអ្វីដែលដូចគ្នា ធ្វើឡើងដូចគ្នា។ នោះហើយគឺជារូបភាព ដែលដូចគ្នា។ តើវាជាអ្វី? ដោយការរួបរួម តែមួយ នោះហើយគឺជាព្រះវិញ្ញាណនៃពេលវេលា គឺ*ការរួបរួម* ។

70 ការរួបរួមគ្នាតែមួយនៅពេលនេះ គឺកំពុងតែបំផ្លាញសាររបស់ព្រះ។ តើពួកគេ បំផ្លាញសារដោយរបៀបណា? តើពួកគេបំផ្លាញព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយ របៀបណា? ពួកគេអាចធ្វើបាន ដោយពុំមានផលប៉ះពាល់ទាល់តែសោះ ដោយ ពុំមានផលប៉ះពាល់ទាល់តែសោះ ដោយការយកទម្លាប់ដូចដែលពួកគេបានធ្វើ ចាប់ តាំងពីការចាប់ផ្តើម ហើយការធ្វើឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់មិនមាន ឥទ្ធិពល។ ឃើញទេពួកគេនិយាយថា "អូ នោះគឺ...ពិតជាបន្ទាប់ពីគ្រប់ទាំងអស់..." អ្នក ឃើញកន្លែង ដែលស្ត្រីដែលមិនមានជំនឿ នោះព្យាយាមធ្វើ...នាង...ខ្ញុំភ្លេច ពី ឈ្មោះរបស់នាងហើយពេលនេះ ប្រសិនបើខ្ញុំអាចគ្រាន់តែហៅឈ្មោះនោះ។ នាង...ខ្ញុំព្យាយាមគិតអស់ជាច្រើនដង។

71 ខ្ញុំកំពុងតែគិតពី បវរកញ្ញាម្នាក់ពីថ្ងៃមុន ខ្ញុំប្រាថ្នាឲ្យយើងមានម្នាក់ងើបឡើង ដូចនោះ។ នាងគឺជាស្ត្រីម្នាក់ដែលបានចូលទៅក្នុង បន្ទប់លក់គ្រឿងស្រវឹង ហើយ បានបំបែកស្រាវីស្គី ហើយបោះបង្ហាញពីទីសម្គាល់ ហើយគ្រប់ទាំងអស់គឺបែបនេះ ហេតុអ្វីមិនមានស្ត្រីងើបឡើងដូចនោះនៅសព្វថ្ងៃនេះ ហើយបានចេញទៅ និង ហែកនូវរូបភាពអាសអាភាសរបស់ស្ត្រីទាំងនេះ នៃប្រជាជាតិសាសន៍របស់នាង ហើយរឿងបែបដូចនោះ? នោះ ពួកគេមិនមានបែប នោះទៀតឡើយ។

72 ឥឡូវ ប៉ុន្តែស្ត្រីម្នាក់នេះ មិនស្មោះត្រង់ជាអ្នកដែលបាននិយាយថា—ថា "ព្រះ គម្ពីរមិនត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញក្នុងការអានតាមសាលាសាធារណៈឡើយ" ហើយ រឿងបែបនោះឯង។

73 ពេលនេះពួកគេក៏ តើអ្នកមានបានកត់ចំណាំម្តងទៀតទេ ឥឡូវពួកគេកំពុង ព្យាយាមនិយាយ ហើយនិស្សិតព្រះគម្ពីរបាននិយាយថា "ទំនាយជាច្រើនដែល ត្រូវបានទាយនៅ ក្នុងបទគម្ពីរគឺពិតជាខុស ហើយមិនដែលកន្លងផុតទៅឡើយ។" ហើយអ្នកបានលឺពីការនោះនិងអានបទគម្ពីរ។ ហើយពួកគេបានព្យាយាមនិយាយ ពីគ្រប់កិច្ចការទាំងអស់ អ្នកឃើញទេ ពួកគេព្យាយាមដើម្បីបំផ្លាញពីឥទ្ធិពលនៃ

ព្រះបន្ទូល។ ប្រសិនបើពួកគេអាចបំផ្លាញ ហើយជំនួសព្រះ បន្ទូលជាលទ្ធិជំនឿ ឬក៏អ្វីមួយដែលមនុស្សមាន នោះហាក់បីដូចជាការយល់ ឃើញរបស់ពួកគេប្រសើរ ជាងព្រះបន្ទូលបន្ទាប់មក ពួកគេបំផ្លាញព្រះបន្ទូល—ដោយប្រពៃណី របស់ពួកគេ។ ហើយនោះជាវិធី ដែលពួកគេព្យាយាមបំផ្លាញ ព្រះបន្ទូលព្រះដោយនយោបាយនិកាយ។

74 ឥឡូវ ក្រុមជំនុំនីមួយៗមានគោលការណ៍របស់ខ្លួន។ ក្រុមជំនុំនៃព្រះជាម្ចាស់មានគោលការណ៍ ក្រុមជំនុំគ្រិស្ទានមាន ហើយនិងបាទីស្ត មេតូទីស និង ព្រីសប៊ីធើរៀនមាន ឥឡូវពួកគេកំពុងតែ ចេញឆ្ងាយពីនោះ ដោយសារតែពួកគេត្រូវបានបែងចែក។ ឃើញទេ ការនេះមិនបានសម្រេចទេកាលពីមុន ពួកគេត្រូវតែធ្វើនៅពេលនេះ។ ឃើញទេ នេះគឺជាពេលវេលានៃការរួបរួម ហើយពេលនេះពួកគេទាំងអស់រួបរួមគ្នា តែមួយ និងជំរុញវាឡើង ហើយនិងឃើញពីលទ្ធផលដែលពួកគេនិងទទួលបាន។ ខ្ញុំអើយវាគឺដូចជាការដុតនំប៉ុងចេញពីសាច់សេះ ហើយនិងស្តេក្តោប មកពីកំប៉ុង ហើយអ្វីដែលវាមានច្រើនរួមគ្នា ហើយរុំវាចូលគ្នា និងដាក់ដំឡូងខ្លះៗ និងគ្រឿងជា ច្រើនទៀតចូលគ្នា ហើយមើលតើអ្នកនិងទទួលបានផលអ្វី។ ខ្ញុំប្រាកដមិនចង់បាន អ្វីពីវាទេ។ ទេ លោក! នោះហើយគឺជាវិធីដែល ពួកគេ កំពុងតែធ្វើ។ ឃើញទេ ពួកគេ កំពុងប្រមូលមនុស្សដែលជឿថាព្រះគ្រិស្តជារឿងនិទានក្រុមជំនុំដែលជឿថា ព្រះយេស៊ូជាជារឿងនិទាន អ្នកផ្សេងទៀត ជឿថាទ្រង់គឺជាព្យាការីម្នាក់។

75 គេនិយាយថា "ថ្ងៃនៃការអស្ចារ្យបានកន្លងផុតទៅ។"

76 ម្នាក់ផ្សេងទៀតនិយាយថា "ប្រហែលជាមានការនោះកើតឡើង។"

77 ហើយ គ្រប់កិច្ចការរួមគ្នា ហើយបទគម្ពីរចែងថា "បើមនុស្សពីរនាក់មិនបានព្រមព្រៀងគ្នា ជាមុនសិនទេ តើគេអាចធ្វើដំណើរជាមួយគ្នាដូចម្តេចកើត?" ឃើញទេ? ពេលនេះ នោះ គឺជាប្រភេទនៃការរួបរួមដែលពួកគេធ្វើ។ ហើយដើម្បី មានព្រះបិតា ដ៏បរិសុទ្ធនៅគ្រប់គ្រងការនេះ ហើយអ្នកទទួលបានរូបភាពនៃទី សម្គាល់ពិតប្រាកដទៅនិងអ្វីដែលបទគម្ពីរបានចែង។ ឥឡូវពួកគេមាន អ្នកដឹកនាំជាលូធើ រៀន ជាក្បាលម៉ាស៊ីន។ ពិតណាស់ យើងឃើញវាជា ពេលវេលា នៃការរួបរួម។ ដូចគ្នាដែរពេលនេះ លទ្ធិកុំម្មុយនីស្ត ហើយនិងគ្រប់ទាំងអស់រួមគ្នា

នៅក្នុងពិភពលោកនិងក្នុងក្រុមជំនុំជាដើមនិងការរួបរួមជាច្រើនទៀត កំពុងតែរួបរួមជាមួយគ្នា។

78 សូមមើល ធម្មជាតិ។ ឱខ្ញុំអើយ! ធម្មជាតិ ប្រសិនបើយើងគ្រាន់តែក្រឡេកមើលធម្មជាតិវាគឺដូចគ្នា។ ធម្មជាតិគឺជាទីសម្គាល់ នៃពេលវេលារបស់ព្រះ ជាម្ចាស់។ តើអ្នកបានដឹងថាជាអ្វីទេ? ព្រយេស៊ូបានប្រាប់ពួកគេឲ្យមើលពីធម្ម ជាតិ។ សមុទ្រនិងរញ្ជួយ ឃើញទេ ហើយនិងមានរឿងខុសគ្នាជាច្រើនទៀត ហើយ និងមានរញ្ជួយដីនៅកន្លែងខុសៗគ្នា ជាតិសាសន៍និងមានជម្លោះ ទីសម្គាល់ជា ច្រើននៅនគរឋានសួគ៌ ទីសម្គាល់នៅលើផែនដី គ្រប់ទីកន្លែងទាំងអស់ និងមានទីសម្គាល់ពីពេលវេលានៃការយាងមក។

79 សូមមើលទៅពពក។ មុនពេលពពកអាចនាំឲ្យមានព្យុះភ្លៀងអ្នកអាចដឹងថាវាដំណើរ ការដោយរបៀបណា? ពពកមួយចំនួនបានប្រមូលផ្តុំគ្នា បង្កើតទៅជាដុំពពកធំ មួយ។ ល្អ ពពកនេះមានខ្យល់បក់មកកាន់វា ពពកមួយផ្សេងទៀតមានខ្យល់បក់ មកកាន់វា ហើយពពកទាំងនោះត្រូវបានខ្យល់បក់រួមគ្នា ហើយក្រោយមកវាបង្កើត ទៅជាខ្យល់ព្យុះ។ ឃើញទេ? ពួកវារួបរួមគ្នាមុនពេលពួកវាអាចង្កើតទៅជាខ្យល់ ព្យុះបាន ពួកវាត្រូវតែរួម។

80 សូមមើលសត្វទា និងសត្វក្ងាន រួបរួមគ្នាតែមួយ មុនពេលពួកវាចាកចេញពីទី កន្លែងរបស់ពួកវា។ ឃើញទេ? ពួកវារួបរួមគ្នា។ អ្នកអាចឃើញពួកវាកំពុងតែហើរ ពីបឹងនេះទៅបឹងនោះ ពីកន្លែងនេះទៅកន្លែងនោះ ពួកវាទាំងអស់គ្នារួបរួមគ្នា។ ពួក វាកំពុងតែរួបរួមគ្នា ត្រៀមរួចជាស្រេចដើម្បីហើរចេញទៅ។ ឃើញទេ វាគឺគ្រាន់តែ... បែបធម្មជាតិ ហើយព្រះជាម្ចាស់បានបង្កើតធម្មជាតិ ហើយធម្មជាតិធ្វើការតាម គម្រោងការរបស់ព្រះជាម្ចាស់។ វាគឺជាច្បាប់របស់ព្រះជាម្ចាស់ ធម្មជាតិទាំងនោះ ធ្វើការស្របទៅតាមច្បាប់របស់ទ្រង់។

81 ដូចជាការអធិប្បាយនៅឯពិធីបុណ្យសព នៃ សារធាតុចិញ្ចឹមដែល បានចូលទៅក្នុងផ្ទះ នៅក្នុងឫសដើមឈើ ដេកនៅទីនោះរហូតដល់រស់ឡើងវិញនៅនិទាឃរដូវ។ វាគឺជាច្បាប់របស់ព្រះជាម្ចាស់។ មិនមានប្រាជ្ញាណា អាចធ្វើឲ្យសារធាតុចិញ្ចឹមចូលទៅក្នុងទីនោះ អ្នកមិនអាចទាញយកវាចេញបាន ឡើយ អ្នកមិនអាចយកទឹកចេញពីវាបានឡើយ មិនមានវិធីប្រសើរណាមួយក្នុងការធ្វើវាបាន ជាជាងព្រះជាម្ចាស់ធ្វើឡើយ។ ព្រះជាម្ចាស់មានវិធីដ៏ល្អឥតខ្ចោះ។ ដូច្នេះ

នៅពេលស្លឹកឈើ ធ្លាក់ចុះ បន្ទាប់មកទ្រង់បានបញ្ចូលសារធាតុនោះចូលទៅក្នុងផ្ទះ ហើយលាក់ វាជិត។ ដូចលោកយ៉ូបបាននិយាយថា "សូមលាក់ទូលបង្គំនៅទីនោះ រហូតដល់ព្រះអង្គស្ងប់ព្រះពិរោធ។" ឃើញទេ? វាបានចូលទៅក្នុងទីនោះដោយ ព្រោះវាគឺជា ច្បាប់ ធម្មជាតិ មុនពេលពេលវាត្រូវស្លាប់។ សូមមើលទៅកាន់ស្លឹកវានៅពេលនេះ ចាប់ផ្តើមធ្លាក់ហើយ។ ហេតុអ្វី? វាគឺជាច្បាប់ធម្មជាតិ។

82 សត្វទា និងរួបរួមគ្នាតែមួយ វាទាំងអស់ ហើយស្ថិតនៅជុំវិញមេដឹកនាំវា។ នៅទីនោះ ពួកវានិងដឹងពីវិធីក្នុងការរួបរួម ខ្ញុំមិនដឹងពីរបៀបដែលពួកវាធ្វើទេ ប៉ុន្តែ ពួកវាដឹងប្រាកដថាទាឈ្មោលគឺជាអ្នកដឹកនាំ។ ហើយទាឈ្មោលតូចនោះដើរតាម ពួកវាទាំងអស់រួបរួមគ្នាហើយស្ថិតនៅជុំវិញទាឈ្មោលនោះហើរឡើងលើអាកាស។ ហើយ វានឹង...មិនដែលចេញពីបឹងនោះឡើយ ប៉ុន្តែវានឹងទៅត្រង់ទៅកាន់ល្វីសៀនណា(Louisianna)ឬក៏រដ្ឋតិចសាស(Texas) ដូចដែលវាអាចទៅបាន ទៅកាន់វាលស្រែ។ ឃើញទេ មុនពេលពួកវាធ្វើការហើរ ចាកចេញ ពីទីលំនៅរបស់ពួកវាជាកន្លែងដែលពួកវាបានកើតនៅឆ្នាំនោះ ពួកវារួមគ្នាតែមួយ។ អាម៉ែន! ដូចជាអ្នកនៅទីនោះ កំពុងតែនៅជិតអ្នកដឹកនាំរបស់ពួកគេ។

83 បញ្ហាតែមួយគឺ ជាមួយមនុស្ស មិនស្គាល់អ្នកដឹកនាំរបស់ខ្លួន។ ហ្នឹងហើយ។ ពួកគេនិងប្រមូលផ្តុំជានិកាយមួយ ពួកគេនិងប្រមូលផ្តុំជា សង្ឃនាយក ឬជាក្រុមមនុស្ស ប៉ុន្តែពួកគេមិនបានប្រមូលផ្តុំនៅជិតមេដឹកនាំរបស់ ពួកគេដែលជាព្រះវិញ្ញាណបរិសុទ្ធនៅក្នុងព្រះបន្ទូលឡើយ។ ឃើញទេ? ពួកគេ និយាយថា "អូខ្ញុំ ខ្លាចក្រែងថា ខ្ញុំនិយាយជ្រុលបន្តិច ខ្ញុំខ្លាចក្រែងថា ខ្ញុំនិងដើរផ្លូវខុស។" អូ គឺនៅទី នេះ! តើអ្វីដែលកូនទានោះបាននិយាយ "ខ្ញុំគ្រាន់តែមិន ចូលចិត្តពីវិធីរក្សាស្លាបរបស់វា។ ខ្ញុំមិនជឿថាខ្ញុំនិងតាមវាឡើយ។" ខ្ញុំនិងត្រជាក់ រហូតដល់ស្លាប់។ ខ្ញុំនិងមិនទៅដល់ទីនោះឡើយ ប្រសិនបើអ្នកមិនបាននាំយក ជាមួយនូវ—នូវការហោះហើរដូចដែលវាបានធ្វើ។ វារួបរួមគ្នាតែមួយ ហើយធម្មជាតិគឺត្រូវធ្វើបែបនោះ។

84 ក្ងានរួបរួមគ្នាតែមួយ ប្រមូលផ្តុំខ្លួនរបស់ពួកវានៅក្បែរមេដឹកនាំវា ពួកវាធ្វើរឿងដូចគ្នា។

85 តើអ្នកធ្លាប់បានកត់ចំណាំទេថា សត្វឃ្មុំផ្តុំគ្នាជាហ្វូង? សត្វឃ្មុំនិងរួបរួមគ្នា ជាហ្វូង គឺនៅជុំវិញម្ចាស់ក្សត្រីរបស់វា។ នោះគឺត្រូវហើយ។ ហើយកន្លែង ណាដែល

នាងទៅពួកវានិងទៅដែរ។ បាទ! តើពួកវាធ្វើអ្វី? ពួកវារួបរួមគ្នាជាហ្វូង។ ប្រាកដណាស់គ្រប់ធម្មជាតិទាំងអស់!

86 ត្រីរួបរួមខ្លួនរបស់ពួកវាមុនពេលអស់ទឹក។ ចេញទៅក្នុងសមុទ្រ អ្នកអាចរកឃើញពួកវា ពួកវាធំ...ដែលយើងហៅថា "សំណើម" ត្រីសូម៉ុង។ នៅពេល ពួកវាមកទីនោះ គឺនៅមុនពេលនិទាឃរដូវមកដល់ អ្នកនិងឃើញវាមាន ចំនួនមួយម៉ឺនក្បាល ចេញពីសមុទ្រនោះ ហែលជារង្វង់ជុំវិញ នៅក្នុងទឹកប្រៃ ប៉ុន្តែពួកវាគឺជាត្រីនៅក្នុងទឹកសាប។ ហើយទីនេះពួកវាមកទឹកសាប ដើម្បីប្រមូល ផ្តុំគ្នានៅរដូវត្រីពង។ ពួកវាទៅទីនោះដើម្បីពងរាងរាល់បួនឆ្នាំម្តង។ ហើយអាចស្លាប់គ្រប់ពេលនៅពេល វាពង។ ហើយពួកវាដឹងពី កន្លែងដែលពួកវាត្រូវស្លាប់ ហើយអ្នកមិនអាចបញ្ឈប់ពួកវា បានឡើយ។ ពួកវានិង លោតតាមជំហ៊ានរបស់ត្រីហើយគ្រប់អ្វីៗទាំងអស់ដឹងថាពួកវានឹងត្រូវស្លាប់។ ប៉ុន្តែច្បាប់ធម្មជាតិបានបង្កើតពួកគេដឹងថានឹងត្រូវទៅទីនោះហើយពងក្នុងរូងហើយស្លាប់។ ហើយត្រីជំនាន់ថ្មីនឹងចេញមកហើយរួម ពួកវាតែមួយបន្ទាប់មកពួកវាចូលទៅសមុទ្រ។ វាគឺជាការរួបរួម! វាគឺជាច្បាប់។ អ្នកមិនអាចប្រឆាំងជាមួយច្បាប់របស់ព្រះជាម្ចាស់ឡើយ។

87 ប្រជាជាតិគឺ—គឺកំពុងតែបែកបាក់ សម្រាប់ពេលវេលានេះយើងឃើញថា—ថាពួកគេមានបំណងធ្វើបែបនេះ។ យើងស្ថិតនៅក្នុងដំណើរ ការនៃការទាស់ទែងគ្នា។ យើងឃើញប្រជាជាតិកំពុងបាក់បែកទំនាក់ទំនងគ្នា។ ពីមួយឆ្នាំទៅមួយឆ្នាំយើងឃើញការ*នេះ*ប្រជាជាតិកំពុងលេចត្របាក់ដោយលទ្ធិកុម្មុនីស្ត ការ*នេះ*កំពុងលេបចូលដោយលទ្ធិកុម្មុនីស្ត។ ហើយនៅទីនេះប្រជាជាតិរបស់យើងវាជា សំបុកឃ្មុំជាមួយលទ្ធិកុម្មុនីស្ត ហើយវានិងគ្រប់គ្រងលើ! ឃើញទេ វានិងធ្វើការនេះ គ្មានវិធីបញ្ឈប់វាបានឡើយ។ ហេតុអ្វី? ដូចទៅនិងមូលហេតុ ដែលអ្នកមិនអាចបញ្ឈប់លោកទីតុសដែរ។ មនុស្សបានបដិសេធព្រះ និងព្រះបន្ទូលរបស់ទ្រង់។ ហ្នឹងហើយដូច្នេះពួកគេនិងធ្វើការនេះ ហើយ យើងឃើញវាកំពុងតែដំណើរការ។

88 ជាធម្មតាខ្ញុំ ខ្ញុំចំណាយពេលពីរបីម៉ោង ខ្ញុំចំណាយពេលអស់ជិតសាប សិបនាទីហើយពេលនេះ។ ឃើញទេ? ប៉ុន្តែដើម្បីបញ្ចប់ការអស់ទាំងនេះ ខ្ញុំគ្រាន់តែប្រញាប់បន្តិច។ អ្នកនិងសិក្សាពីការនេះ នៅពេលអ្នកទៅដល់ផ្ទះ។

89 សូមកត់ចំណាំ ពួកគេកំពុងតែរួបរួមគ្នាពេលនេះ។ អ្នកនិយាយ "បងប្រុស ប្រានហាំតើជាការពិតទេ?" ពួកគេកំពុងមកធ្វើសង្គ្រាមនៅអើម៉ាគេដូន ពិតណាស់

តើពួកគេនឹងធ្វើអ្វី។ ឃើញទេ? ហើយពួកគេរួមគ្នាសម្រាប់ការនោះពេលនេះ។ ដូច្នេះហើយ បានជាយើងមានអង្គការសហប្រជាជាតិ ហើយយើងមានជាច្រើនទៀត។ ការរួបរួមភាគខាងលិចប្រឆាំងទៅនិង ភាគខាងកើត លទ្ធិកុម្មុនីស្ត ជាដើមទាំងអស់នេះកំពុងតែរួបរួមគ្នា។ ក្រុមជំនុំទាំងអស់កំពុងតែរួបរួមគ្នា។ គ្រប់អ្វីៗទាំងអស់ហាក់បីដូចជារួបរួមគ្នា។ ការរួបរួម ការរួបរួមខ្លួនរបស់ពួកគេតែមួយ យើងឃើញ ពីការនោះ។

90 ហើយក៏ នៅខណៈពេលនៃការរួបរួមនៃជាតិសាសន៍ទាំងនេះ ទីសម្គាល់ទាំងនេះ ទីសម្គាល់ជាតិសាសន៍ យើងឃើញនៅក្នុងពិភពលោកមាន រញ្ជួយដីកន្លែងផ្សេងៗ មានការខុសគ្នាជាច្រើនកំពុងរួបរួមគ្នា នាំយកពិភពលោករួមគ្នា នាំមនុស្សមករួមគ្នា ក្រុមជំនុំទាំងអស់រួមគ្នា គឺគ្រប់ការទាំងអស់នេះ។ ហើយខណៈដែលគ្រប់ការទាំងនេះកំពុងតែរួបរួមគ្នា មានការរួបរួមផ្សេងទៀតកំពុង តែបន្តកើតឡើង។ អាម៉ែន! នោះហើយគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់ប្រាប់អ្នកនៅពេលនេះ។

91 ព្រះជាម្ចាស់គឺកំពុងរួបរួមកូនក្រមុំរបស់ទ្រង់។ នាងគឺកំពុងតែរួបរួមគ្នា ពីទិសខាងកើតទៅដល់ទិសខាងលិច ហើយពីទិសខាងជើងដល់ទិសខាងត្បូង។ នេះគឺ ជាពេលនៃការរួបរួមគឺដល់ពេលហើយឥឡូវនេះ។ តើនាងរួបរួមដើម្បីអ្វី? ការលើកឡើង។ អាមែន!ព្រះរៀបចំនាងរួចជាស្រេច។ ហ្នឹងហើយ ការរួបរួម! តើនាងរួបរួមជាមួយនរណា? ជាមួយព្រះបន្ទូល! "ផ្ទៃមេឃ និងផែនដីនឹងរលាយបាត់ទៅ តែពាក្យដែលខ្ញុំនិយាយមិនរលាយបាត់ទេ។" នាងគឺបានរួបរួមខ្លួនរបស់ពួកនាងជាមួយនិង**ព្រះបន្ទូលរបស់ព្រះជាម្ចាស់** ដោយពុំមានអ្វីពីនិកាយឬក៏នរណាម្នាក់និយាយឡើយ។ នាងបានរួបរួម ខ្លួនរបស់ពួកនាង។ នាងគឺត្រៀមខ្លួន រួចរាល់ហើយ។ ហេតុអ្វី? នាងគឺជាកូនក្រមុំ។ ត្រូវហើយ។ ហើយនាង គឺកំពុងតែរួបរួមខ្លួន នាងជាមួយនិង កូនកម្លោះរបស់នាង ឃើញទេ ហើយកូន កម្លោះគឺជាព្រះបន្ទូល។ "កាលពីដើមដំបូងបង្អស់ព្រះបន្ទូលមានព្រះជន្មគង់នៅ។ ព្រះបន្ទូលគង់នៅជាមួយព្រះជាម្ចាស់ ហើយព្រះបន្ទូលជាព្រះជាម្ចាស់ ព្រះបន្ទូលបានកើតមកជាមនុស្ស ហើយគង់នៅក្នុងចំណោមយើងរាល់គ្នា។"

92 ហើយ ក្រុមជំនុំ និងកូនក្រមុំនិងព្រះបន្ទូលគឺតែមួយ រហូតទាល់តែព្រះបន្ទូលតែមួយគត់គឺធ្វើការសម្រាប់កិច្ចការរបស់កូនកម្លោះ។ អាម៉ែន! អ្នកឃើញការនេះទេ? ការរួបរួមមួយ! មិនមានអ្វីច្រើនទៀតទេ "ចូលរួមជាមួយក្រុមជំនុំ" មិនមាន

ច្រើនជាង *នេះ* ទេ ប៉ុន្តែ គេចពីអ្វីទាំងអស់ ហើយចូលទៅជិតព្រះយេស៊ូគ្រិស្ត។ ឃើញទេ? វាគឺជាពេលវេលានៃការរួបរួម។ ព្រះជាម្ចាស់ រួបរួមកូនក្រមុំរបស់ទ្រង់ជា មួយគ្នា នាំការរួបរួមត្រឡប់មកវិញ គឺពិតប្រាកដណាស់។ ការរួបរួមព្រះបន្ទូលសន្យារបស់ទ្រង់។

93 ថេស្សាឡូនិចខ្សែទី២ ជំពូកទី២ មានបន្ទូលថា ប្រាំជំពូកនេះបានចែងថា "មានមនុស្សជាច្រើនដែលស្ថិតនៅក្នុងផ្នូរនឹងរស់ឡើងវិញ។ ហើយយើងនិងរួបរួមជាមួយពួកគេ (អ្នកដែលមានជីវិត ជាមួយអ្នកដែលបានស្លាប់) និងរួបរួមមុនពេលយើងក្រោកឈរនៅទីនោះ" ដោយព្រោះកូនក្រមុំនិងបំពេញគ្រប់កិច្ចការនៅពេលនាងទៅដល់ទីនោះ។ ម្នាក់ដែលរស់នៅ ដែលកំពុងរួបរួមខ្លួន របស់ពួកគេជាមួយព្រះបន្ទូល ហើយអ្នកដែលបានស្លាប់ទៅហើយបានធ្វើការនោះ ហើយរួបរួមគ្នាតែមួយ បង្កើតជាសហព័ន្ធដ៏អស្ចារ្យមួយ នៃការរួបរួមមុនពេល ការរួបរួមនៅទីនោះ។ អាម៉ែន!

94 លទ្ធិកុម្មុនីស្តត្រូវតែងើបឡើង រឿងផ្សេងអស់ទាំងនេះត្រូវតែងើបឡើង ហើយក្រុមជំនុំត្រូវតែរួបរួមតែមួយពីការនៅឯនាយ នៅពេលការទាំងនោះ...ហើយប្រជាជាតិទាំងអស់ប្រមូលផ្តុំនៅទីនោះជាក្រុមប្រឹក្សាក្រុមជំនុំពិភពលោក ហើយកូនក្រមុំត្រូវតែរួបរួមដោយនៅក្រោមព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដើម្បីធ្វើកិច្ចការបែបនោះ ព្រះជាម្ចាស់បានប្រទានទីសម្គាល់ឋានសួគ៌ និងជាច្រើនទៀត ដែល បញ្ជាក់ទៅដល់ក្រុមជំនុំ ដែលទ្រង់ត្រូវតែមានប្រជាជាតិមួយ។ អាមែន!

95 ព្រះជាម្ចាស់ពេលវេលានៃការរួបរួម! ត្រូវហើយ ឱខ្ញុំអើយ! ពេលនេះ សូមចងចាំថាមានការរួបរួមមួយនៃព្រះបន្ទូល (ការរួបរួមត្រឡប់មកវិញ) នាំយកត្រឡប់មកវិញ "ជំនឿនិងផ្តល់ឲ្យដល់អ្នកដែលបរិសុទ្ធ។" ការនាំយកត្រឡប់មកវិញ! នោះជាការតែមួយអាចត្រូវបានធ្វើនៅសព្វថ្ងៃនេះ។ ជាពេលតែមួយដែលត្រូវបាន ធ្វើនាពេលនេះ។ វាមិនត្រូវបានប្រឆាំងនៅកន្លែងណាទៀតឡើយពួកគេបានចាក ចេញទៅនៅជាមួយនិកាយ។ ប៉ុន្តែនាពេលនេះ វាមិនមែនជាកម្មសិទ្ធិនៃនិកាយ ទៀតឡើយ ពីព្រោះវាជាពេលសម្រាប់ការរួបរួមនៃមនុស្សប្រុសនិងស្ត្រីគ្រប់ ជាតិសាសន៍ទាំងអស់ គ្រប់ពណ៌សម្បុរ គ្រប់លទ្ធិជំនឿ គ្រប់អ្វីៗទាំងអស់នៅក្រោម ព្រះគ្រិស្តដោយការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ ហើយត្រឡប់ទៅកាន់ព្រះ បន្ទូល។

96 ពេលវេលានៃការរួបរួមសម្រាប់ក្រុមជំនុំ! ឱ ខ្ញុំអើយ! ការរួបរួមគ្រប់ទាំងព្រះបន្ទូលដែលបានផ្សព្វផ្សាយទៅកាន់គ្រប់ប្រទេសដោយអង្គការទាំងនេះ ចាប់តាំងពីនីសៀ រ៉ូមនៅពេលពួកគេបានបង្កើតក្រុមជំនុំជាលើកដំបូង ពួកគេរៀបចំក្រុមលូធើ ពួកគេរៀបចំវេស្លី ពួកគេរៀបចំគ្រប់ទាំងក្រុមជំនុំទាំងអស់។ ហើយការធ្វើបែបនោះ ពួកគេត្រូវតែគោរពតាមលទ្ធិជំនឿ ហើយក្រោយមក នៅពេលព្រះជាម្ចាស់ប្រទានអ្វីមួយផ្សេងទៀត ពួកគេ មិនអាចទទួលយកវាទេ។ ដូចនេះហើយ វាមិនអាចទៅរួចរហូតដល់ពេលឥឡូវនេះ។ ហើយព្រះជាម្ចាស់សន្យា នៅថ្ងៃចុងក្រោយថា "ជំនឿនៃព្រះវរបិតានិងត្រូវបានស្តារឡើងវិញទៅកាន់កូនក្រមុំម្តងទៀត" ដែលវា និងមានតែវិធីនេះ ហើយវាមិនមែនពេលផ្សេងទៀតឡើយ ប៉ុន្តែគឺពេលនេះ។ សូមមើលតើអ្វីជាទីសម្គាល់មកពីឋានសួគ៌ ជាដុំភ្លើងនៅក្នុងចំណោមយើង ហើយជាមួយនិងទីសម្គាល់ជាច្រើនទៀត និងភាពអស្ចារ្យរបស់ព្រះអម្ចាស់យេស៊ូគ្រិស្ត។ ហើយខណៈដែលទ្រង់មានបន្ទូលមកកាន់យើង ភាពល្អឥតខ្ចោះស្ថិតស្ថេរជារៀងរហូត។ អាម៉ែន! ក្រោយមក យើងឃើញកន្លែងដែលយើងកំពុងតែឈរ។ ពេលវេលានៃការរួបរួម!

97 យើងឃើញប្រជាជាតិជាច្រើនកំពុងរួបរួម យើងឃើញការរួបរួមពិភពលោក យើងឃើញការរួបរួមលទ្ធិកុម្មុនីស្ត យើងឃើញការរួបរួមរបស់ក្រុមជំនុំ ហើយយើង ឃើញការរួបរួមរបស់ព្រះជាម្ចាស់ដោយអង្គទ្រង់ជាមួយកូនក្រមុំរបស់ទ្រង់រហូត ទាល់តែទ្រង់និងក្រុមជំនុំគឺតែមួយដូចគ្នា។ ហាលេលូយ៉ា! ដូចជាពីរ៉ាមីតនៅទីនោះ។ ពិតណាស់! ការរួបរួមខ្លួនរបស់ពួកគេតែមួយ ការរួបរួមរបស់ព្រះ ជាម្ចាស់! ហេតុអ្វី?មិនធ្លាប់មានពីមុន ចាប់តាំងពីអាយុកាលដំបូងរបស់ក្រុមជំនុំគឺ ជាដុំភ្លើងនៅក្នុងចំណោមមនុស្សទាំងអស់។ មិនធ្លាប់មានពីមុន ចាប់តាំងពីសម័យកាលរបស់ក្រុមជំនុំ តើពួកគេធ្លាប់ឃើញពីការទាំងនេះ ដែលយើងកំពុងឃើញនៅថ្ងៃនេះទេ។ ហើយការនេះតែមួយគត់ដែលអាចធ្វើទៅរួច នៅពេលព្រះជាម្ចាស់បានប្រទានត្រាទាំងប្រាំពីរ ហើយបានប្រទានទីសម្គាល់ដល់ យើងដោយត្រានេះហើយបានប្រទានទេវតាទាំងប្រាំមួយចុះមកពីឋានសួគ៌ ហើយយាងមកយក ព្រះបន្ទូលដែលខ្ចាត់ខ្ចាយទៅតាមនិកាយរបស់ពួកគេ ហើយចងផ្គុំវាជា ព្រះបន្ទូលរបស់ព្រះជាម្ចាស់ម្តងទៀត ដើម្បីនាំយកព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ឲ្យចុះមក។

98 ព្រះយេស៊ូមានបន្ទូលថា "បើអ្នករាល់គ្នាស្ថិតនៅជាប់នឹងខ្ញុំ ហើយបើពាក្យ

ខ្ញុំ នៅជាប់នឹងអ្នករាល់គ្នា ចូរទូលសុំអ្វីៗតាមតែអ្នករាល់គ្នា ប្រាថ្នាចង់បានចុះ នោះអ្នករាល់គ្នាមុខតែបានទទួលជាមិនខាន។" រួបរួមកូនក្រមុំឡើងវិញជាមួយ ព្រះបន្ទូល គឺជាព្រះជាម្ចាស់។ ក្រុមជំនុំនិងព្រះបន្ទូលមិនមែនក្រុមជំនុំនិងគោល លទ្ធិទេ។ អូ ខ្ញុំអើយ! តើ...ស្តារអ្វីឡើងវិញ? សេចក្តីជំនឿនៃឪពុកដើមពេនតេ កុស្ត ឃើញទេ ដែលបានផ្សព្វផ្សាយដោយក្រុមលូធើ។ មិនមែនលូធើខ្លួនឯង នោះទេ មិនមែនលូធើទេ មិនមែនវេស្លី មិនមែនដោយពួកអ្នកបង្កើតដ៏អស្ចារ្យ ទាំងនោះទេ។ ប៉ុន្តែបន្ទាប់ពីក្រុមរបស់ពួកគេ ចេញឆ្ងាយទៅ មានក្រុមជំនុំមួយ បានលេចឡើង ហើយពួកគេ...តើពួកគេបានធ្វើ អ្វីជាមួយការនោះនាពេលក្រោយ មកទៀត ពួកគេបង្កើតអង្គការមួយទៀតក្រៅពី អង្គការនេះ។ ពួកគេបានទទួល គោលលទ្ធិជំនឿ ហើយនិងជាច្រើនទៀត ហើយ ពួកគេបានចាកចេញឆ្ងាយទៅ។ ហើយសូមក្រឡេកមើលទៅកាន់ពួកគេថ្ងៃនេះ ពេលនេះពួកគេបានក្លាយជាបែប នោះហើយ គឺទីប្រឹក្សាក្រុមជំនុំពិភពលោក។

99 ឥឡូវ អ្នកឃើញទេ ប៉ុន្តែនៅថ្ងៃចុងក្រោយ អ្នកឃើញទេ យើងឃើញរឿងជា ច្រើនកំពុងកើតឡើងនាពេលនេះ ដែលមិនធ្លាប់កើតមានពីមុនមក។ ឃើញទេ វា គឺ ជាទីសម្គាល់របស់ព្រះជាម្ចាស់ ហើយការរួបរួមទាំងនេះគឺជាទីសម្គាល់នៃពេល វេលា។ ពេលនេះ យើងចង់ក្រឡេកមើលការនោះដោយប្រុងប្រយ័ត្ន ហើយត្រូវតែ ប្រាកដថា យើងឃើញពីវា។ ការចាកចេញ...ពួកគេចាកចេញពីសេចក្តីពិតនៃព្រះ បន្ទូលទៅកាន់និកាយ ដើម្បីទទួលគោលលទ្ធិ ហើយនិងគំនិតនៃមនុស្ស ខុសៗគ្នា ជំនួសឲ្យការទទួលយកព្រះបន្ទូល។

100 វិវរណៈជំពូកទី១០បានថែងពី "សាររបស់ទេវតាទីប្រាំពីរ។" ពេលនេះ ចូរ ចាំ ពីត្រែទាំងប្រាំពីរ ហើយមានទេវតាប្រាំពីរផ្លុំត្រែប្រាំពីរនោះ។ នោះគឺជាអ្វីដែល យើង និងរៀនបន្ត។ ប៉ុន្តែសូមចងចាំពីកន្លែងយ៉ាងពិសេសថា "ទេវតា..." មិនមែនត្រែ ទីប្រាំពីររបស់ទេវតាទេប៉ុន្តែជា"សាររបស់ទេវតាទីប្រាំពីរ។" ឃើញទេ មិនមែនត្រែ របស់ទេវតាទេ ជាសាររបស់ទេវតា! ឃើញទេ ទេវតាគ្រាន់តែផ្តល់ សម្លេងពីត្រែ ពីទេវតាទីប្រាំពីរនោះ ទេវតាត្រែ ប៉ុន្តែបាននិយាយថា "នៅក្នុងថ្ងៃរបស់សាររបស់ ទេវតាទីប្រាំពីរ" ឃើញទេ នៅពេលដែលសាររបស់គាត់ត្រូវបានបញ្ចប់។ ឃើញទេ នោះគឺសម័យកាលសាររបស់ក្រុមជំនុំ។ នៅក្នុងពេលនេះ ក្រោយមក គាត់និង...

រាជសារ មិនមែនជាត្រៃឡើយ ហើយ "អាថ៌កំបាំងរបស់ព្រះ (ដែលបានសរសេរនៅក្នុងព្រះបន្ទូល)គួរតែសម្រេច។"

101 ឥឡូវសូមក្រឡេកមើលពីថ្ងៃដែលយើងកំពុងរស់នៅ! សូមក្រឡេកមើលទៅកាន់គ្រានោះ ថាតើការនោះបាននាំឲ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់ខ្ចាត់ខ្ចាយយ៉ាង ណា តើលូធើហើយគ្រប់ក្រុមទាំងអស់របស់ពួកគេ ដែលពួកគេគឺជាអ្នកកំណែទម្រង់ដ៏អស្ចារ្យរួចទៅហើយ ត្រឡប់មកវិញហើយបានបង្ហាញវានៅក្នុងបទគម្ពីរ ជា កន្លែងដែលពួកគេនិងធ្វើបែបនោះ គ្រប់មនុស្សទាំងអស់ត្រូវនិងចំនុចរបស់គាត់ អ្វីដែលគាត់និងធ្វើ ហើយតើអ្វីដែលនិងកើតឡើងទៅកាន់ក្រុមជំនុំ តើគាត់និងធ្វើអ្វី ហើយតើអ្វីនិងកើតឡើងទៅកាន់ក្រុមជំនុំ គ្រប់ទាំងកិច្ចការទាំងនេះ គាត់បានបញ្ឈប់។ ហើយក្រោយមក នៅថ្ងៃចុងក្រោយបង្អស់ នៅពេលយើងមិនបានដឹងអ្វី ទាំងអស់អំពីការនេះ បានប្រាប់យើងជាមុនពីការកើតឡើងដ៏ជាក់លាក់ ហើយសូម្បីតែនៅក្នុងកាសែត ហើយរឿងទាំងនេះត្រូវបានកត់ចំណាំ ហើយគាំទ្រ និងបង្ហាញការនេះ ហើយចងក្រងការលាក់កំបាំងជាមួយគ្នា។ អាម៉ែន! បងប្អូនប្រុសការនោះគឺវិសេសណាស់ដល់ខ្ញុំ! ការនោះសម្រាប់ខ្ញុំ គួសបញ្ជាក់ពីព្រះបន្ទូល។ អាម៉ែន! ខ្ញុំមិនខ្វល់ពី—ពីឬក៏ ខ្ញុំពិតជាយកចិត្តទុកដាក់ពីអ្វីដែលមនុស្សនិយាយ គិតថាត្រឹមត្រូវណាស់ ប៉ុន្តែសម្រាប់ខ្ញុំវាគឺជាសេចក្តីពិត។

102 ដូចជាអ្នកប្រាជ្ញដែល មកពីទីក្រុងប៉ាប៊ីឡូន ពួកគេបានស្រែក "តើទ្រង់នៅឯណា ស្តេចដែលចាប់កំនើតនៃសាសន៍យូដា? ទ្រង់គឺគង់ នៅលើផែនដីនៅពេលនេះ។ យើងត្រូវតែស្វែងរកទ្រង់។" ត្រូវហើយ ហើយខ្ញុំជឿថាទ្រង់យាងមកជិតដល់ហើយ ដែលខ្ញុំអាចនិយាយបានថា "មើលកូនកម្លោះមកដល់ហើយ! ខ្ញុំលឺសម្រែកស្រែកឡើងពាក់កណ្តាលអធ្រាត្រ!" អាម៉ែន! យើងស្ថិត ចំពេលវេលានៃទីបញ្ចប់ហើយ។ អូ ខ្ញុំអើយ ជាពេលវេលាដែលយើងកំពុងតែ រស់នៅ។ សូមកត់ចំណាំ។ ឃើញទេ?

103 នេះពិតជាថ្ងៃល្អ! ជាពេលដ៏ល្អដែលយើងកំពុងតែរស់នៅសំរេចតាមគំរោងការដ៏លាក់កំបាំងរបស់ព្រះអង្គនឹងត្រូវបានសម្រេច ការនាំយកភាពជាព្រះ ការបង្ហាញ តើការនោះគឺជាអ្វីនៅពេលនេះ តើគោលលទ្ធិតូចទាំងនេះ និងបានឆ្ពោះទៅមុខ ហើយនិងធ្វើឲ្យទ្រង់សម្រេចការ *នេះ* យ៉ាងណា ហើយតើនរណាបានធ្វើកិច្ចការ ទ្រង់ *នេះ* ហើយនរណាបានធ្វើកិច្ចការ*នោះ* ដល់ទ្រង់។ ប៉ុន្តែ ទេវតានៃ

ព្រះអម្ចាស់ បានយាងចុះមក ហើយបាននាំយកគ្រប់ទាំងគោលលទ្ធិរបស់ពួកគេ និងបានជំ រុញសេចក្ដីពិតចេញមក និងបានបង្ហាញពីការនេះ។ នោះហើយគឺជាកិច្ចការហ្នឹង គ្រាន់តែល្អតតខ្ចោះតាមតែវាអាចធ្វើបាន មិនវិធីផ្សេងទៀតណាដែលអាចអាចទៅបានឡើយ។ នោះហើយគឺជាការហ្នឹង ដែលនោះគឺជាទ្រង់។ ឃើញទេ គ្រាប់ពូជ ដែលខូច គ្រប់—គ្រប់ការទាំងអស់នេះគឺខុសពីគ្នាដែលពិតជាការលាក់កំបាំងក្នុង ចំណោមមនុស្ស។ ឃើញទេ? តើនេះគឺជាអ្វី! ទ្រង់បាន...នេះគឺជាទីសម្គាល់ សម្រាប់អ្វី? រួបរួម!

104 តើទ្រង់បានមានបន្ទូលអ្វីនៅក្នុងម៉ាឡាគីជំពូកទី៤? ស្ដារឡើងវិញ! ស្ដារឡើងវិញពីសេចក្ដីជំនឿនៃបុណ្យថ្ងៃទីហាសិប ត្រឡប់ទៅកាន់មនុស្សជាមួយនិង សារនៃបុណ្យទីហាសិប ទីសម្គាល់នៃបុណ្យទីហាសិបដូចគ្នា ភស្តុតាងពីបុណ្យទី ហាសិនដូចគ្នា ព្រះតែមួយដូចគ្នា អំណាចដូចគ្នា ការបង្រៀនដូចគ្នា ពិតជាដូចគ្នា ទាំងអស់ជាមួយនិងការការពារនៃដុំភ្លើងដូចគ្នា ដែលធ្វើឲ្យលោកសូលគាំងជាប់ តាមផ្លូវ ផ្លូវទៅក្រុងដាម៉ាស គឺស្ថិតនៅក្នុងចំណោមយើង ការធ្វើរឿងដូចគ្នាទ្រង់ បានធ្វើនៅថ្ងៃនោះ។ ការរួបរួម!

105 យើងឃើញប្រជាជាតិ ជាច្រើនកំពុងតែរួបរួម យើងឃើញពិភពលោកកំពុងតែរួបរួម យើងឃើញក្រុមជំនុំកំពុងតែរួបរួម។ យើងឃើញកូនក្រមុំកំពុងតែរួបរួម ការរួបរួមជាមួយនិងព្រះបន្ទូល។ ហេតុអ្វី?ព្រះបន្ទូលគឺជាព្រះជាម្ចាស់។ ហើយព្រះបន្ទូលជា...ជាកូនកម្លោះ (ជាព្រះបន្ទូល) ហើយកូនក្រមុំ (ជាអ្នកឮពីព្រះបន្ទូល) ពួកគេរួបរួមគ្នាជាក្រុមមួយ។ ពួកគេរួបរួមដូចជាពិធីរៀបការមួយ។ ឃើញទេ ពួកគេត្រៀមខ្លួនរួចជាស្រេចសម្រាប់ពិធីរៀបការ ហើយពួកគេ—ពួកគេ ក្លាយទៅជាតែមួយ។ ព្រះបន្ទូលក្លាយទៅជាអ្នក អ្នកក្លាយទៅជាព្រះបន្ទូល។ ព្រះយេស៊ូមានបន្ទូលថា "នៅថ្ងៃនោះ អ្នករាល់គ្នានឹងដឹង។ ទាំងអស់របស់ព្រះវរបិតា គឺខ្ញុំហើយទាំងអស់របស់ខ្ញុំ គឺអ្នករាល់គ្នា ទាំងអស់របស់អ្នករាល់គ្នាគឺខ្ញុំ។ នៅថ្ងៃនោះអ្នករាល់គ្នានឹងដឹងថា ខ្ញុំនៅក្នុងព្រះបិតារបស់ខ្ញុំ ហើយអ្នករាល់គ្នានៅក្នុងខ្ញុំ ខ្ញុំក៏នៅក្នុងអ្នករាល់គ្នាដែរ។" ឃើញទេ? នៅ "ថ្ងៃនោះ។" ជាថ្ងៃអ្វី? ថ្ងៃនេះ! យើងរកឃើញពីការលាក់កំបាំងដ៏អស្ចារ្យនៃព្រះជាម្ចាស់ត្រូវបានបើកសម្ដែង។ អូ ខ្ញុំពិតជាពេញចិត្តការនោះណាស់!

106 អូ មើលថាតើវិទ្យាសាស្ត្រ និងព្រះបន្ទូលមិនអាចប្រៀបធៀបគ្នាបានយ៉ាងណា

ដូចជាពួកគេធ្វើនៅសព្វថ្ងៃនេះ។ ពួកគេមិនអាចធ្វើបានទេកាលពីមុន។ គឺទើបតែពេលនេះទេដែលពួកគេអាចធ្វើបាន។

107 សូមកត់ចំណាំទ្រង់មានបន្ទូលថា "ទីសម្គាល់ឋានសួគ៌ ទីសម្គាល់ឋានសួគ៌។" វិទ្យាសាស្ត្រ និងទីសម្គាល់ជាច្រើន ឥឡូវពួកគេបានទីសម្គាល់ដ៏អស្ចារ្យមួយនៅលើមេឃសព្វថ្ងៃនេះ ពួកគេមានអវកាសយានិក និងគ្រប់អ្វីៗទាំងអស់។ ប៉ុន្តែ តើអ្វីដែលពួកអវកាសយានិកទាំងនេះ ធ្វើទៅកាន់វិទ្យាសាស្ត្រពិភពលោក? វាគឺនាំមកនូវការភ័យខ្លាច។ ពួកគេមិនបានដឹងពីពេលវេលាដែលពួកគេអាចបញ្ជូនអ្វីមួយ ដូចនោះ ហើយគ្រាន់តែបំបែកការនេះ ហើយពួកគេមិនអាចធ្វើបានទៀតឡើយ។ ឃើញទេ? ពេលនេះទីសម្គាល់នោះ ដែលពួកគេទទួលបាន ជាទីសម្គាល់ពេញ ដោយសេចក្តីខ្លាចពីឋានសួគ៌។ ឃើញទេ? ពួកគេទទួលបានសញ្ញា កាំជ្រួចគ្រាប់ បែកបរមាណូ និងគ្រប់អ្វីៗទាំងអស់ ជាប្រភេទនៃទីម្គាល់។

108 អ្នកឃើញពីកន្លែងដែលពួកគេបានផ្តល់ទីសម្គាល់នេះ—សន្ធិសញ្ញានេះ នៅថ្ងៃក្រោយ ដែលពួកគេនិងមិនធ្វើឲ្យមានការផ្ទុះគ្រាប់បែកទៀតឡើយ ប៉ុន្តែពេលនេះពួកគេបានចុះទៅក្នុងទឹកហើយចូលទៅក្រោមដីជាការពិសោធដូចគ្នា។ ឃើញទេ? ពួកគេបានចុះសន្ធិសញ្ញា "យើងនិងមិនធ្វើការនេះឡើយ ប្រសិនបើ អ្នកនិយាយថា អ្នកនិងមិនធ្វើវា (ប៉ុន្តែអ្នកនិងត្រឡប់ទៅវិញ ហើយធ្វើវាដោយវិធីនេះខណៈពេលដែលយើងដឹងថាអ្នកនិងធ្វើកិច្ចការនេះនូវវិធីដូចគ្នានៅទីនោះ)។" ឃើញទេ? វាមិនគ្រាន់តែជារឿង វាគឺគ្រាន់តែ...មិនមានជំនឿនៅក្នុងចំណោមពួក គេមិនមាន—មិនមានអ្វីទាំងអស់។ អ្នកអាច...ឃើញទេ? ហើយភាពភ័យខ្លាច របស់មនុស្សគ្រប់គ្នាពីមនុស្សម្នាក់ទៀត។ នោះគឺជាទីសម្គាល់នៃភាពភ័យខ្លាច។

109 វិទ្យាសាស្ត្រ ហើយនិងមនុស្ស និងប្រជាជាតិនានាបានបង្កើតទីសម្គាល់នៃភាពភ័យខ្លាចនៅលើមេឃ។ នោះគឺជាការពិត។ ពេលនេះ គឺជាការភ័យខ្លាចពីអ្នក ផ្សេងទៀត។ ហើយមានទីសម្គាល់ឋានសួគ៌បានផ្តល់ឲ្យទៅ...ឃើញពេល នេះទេ ពួកគេក៏ទទួលបាន ទីសម្គាល់ពីឋានសួគ៌ដែរ ជាទីសម្គាល់នៃភាពភ័យខ្លាចមនុស្សម្នាក់នៅក្នុងយានអវកាស ប្រហែលជាមានគ្រាប់បែកបរមាណូ ហើយអាចទម្លាក់និងកម្ទេចប្រជាជាតិទាំងមូល។ ក្រោកឈរនៅក្នុងយានអវកាស និងគួរឲ្យកត់ចំណាំនៅទីនោះ។ មិនមានអ្វីអាចបញ្ឈប់ពួកគេពីការធ្វើបែបនោះឡើយ។ ពួកគេប្រាកដជាអាចធ្វើវាបាន ពួកគេ...គ្រប់ពេលដែលពួកគេចង់ធ្វើ។ ពួកគេអាចធ្វើ

ឲ្យ ប្រជាជាតិក្លាយទៅជាធូលីដី ប្រសិនបើពួកគេចង់ធ្វើ ប៉ុន្តែ...នៅក្នុងរយៈ ពេលដប់ ប្រាំនាទីចាប់ពីពេលនេះទៅ។ តើគេអាចធ្វើអ្វីបាន ម្នាក់ទៀតក៏ធ្វើបែបនោះដែរ។ ដូច្នេះហើយ អ្នកឃើញថាពួកគេទទួលបានទីសម្គាល់មួយ ប៉ុន្តែទីសម្គាល់ប្រភេទនោះគឺធ្វើឲ្យពួកគេខ្លាច។

110 ពួកគេកំពុងតែរួបរួមគ្នា ការដាក់អំណាចរួបរួមរបស់ពួកគេតែមួយ។ ពិភពលោក ដែលមានសេរីភាព ពួកគេបានដាក់អំណាចរបស់ពួកគេរួមគ្នា។ លទ្ធិ កុំម្មុនីស្ត បានដាក់អំណាចរបស់ពួកគេរួមជាមួយរុស្ស៊ី។ ប៉ុន្តែគឺជាភាពភ័យខ្លាច របស់មនុស្សគ្រប់គ្នាទៅលើមនុស្សម្នាក់។ ឃើញទេ វាគឺជាទីម្គាល់នៃភាពភ័យ ខ្លាច។ នោះគឺពិតជាត្រឹមត្រូវណាស់។ នោះគឺជាទីសម្គាល់ជាតិនិងជាច្រើនទៀត។

111 ប៉ុន្តែក្រុមជំនុំបានទទួល ទីសម្គាល់មកពីឋានសួគ៌ ជាអាវកាសយានិកម្នាក់! អាម៉ែន! ព្រះយេស៊ូគ្រិស្ត នៅក្នុងទម្រង់ជាដុំភ្លើង ដែលទ្រង់ពេលនោះស្ថិតនៅក្នុងបទគម្ពីរសញ្ញាចាស់ ដែលនៅពេលនោះ ទ្រង់បានជួបសូលនៅតាមផ្លូវទៅកាន់ទីក្រុងដាម៉ាស ដូចព្រះយេស៊ូនៅសព្វថ្ងៃនេះ! ហើយតើការនោះបានធ្វើអ្វី? តើការការនោះបាននាំឲ្យមានសេចក្តីភ័យខ្លាចឬ? វានាំមកនូវសេចក្តីស្រឡាញ់ ការរួបរួមជាមួយនិងម្នាក់ផ្សេងទៀត។ អាម៉ែន! ការមានអារម្មណ៍ទៅកាន់នរណាម្នាក់។ វាគឺ នាំមកនូវសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់ អូ រួបរួមយើង និងនាំយកយើងឲ្យក្លាយជារាងកាយនៃព្រះគ្រិស្ត ជាការរួបរួមមួយដូចជាកូនក្រមុំ។ នោះហើយគឺជាអ្វីដែល កំពុងតែធ្វើនាពេលនេះ នោះគឺជាការរួបរួមមួយដែលព្រះជាម្ចាស់...

112 ពួកគេកំពុងរួបរួមខ្លួនរបស់ពួកគេ មួយក្រុមនៅ*ទីនេះ* ដើម្បីប្រឆាំងទៅនិងក្រុមមួយទៀត មួយក្រុមនៅ*ទីនោះ* ដើម្បីប្រឆាំងទៅនិងក្រុមមួយទៀត។ ក្រុមជំនុំនៅទីនេះគឺកំពុងតែឈររវាងពួកយើង អ្នកមើលតើមានអ្វីកើតឡើង។ និងមានការរួបរួមជាមួយពួកគេ។ នោះគឺពិតជាត្រឹមត្រូវណាស់។ ប៉ុន្តែ ឥឡូវ យើងរកឃើញថាការនោះគឺនាំមកនូវភាពភ័យខ្លាច ហើយនិងភាពវង្វេង។

113 ប៉ុន្តែក្រុមជំនុំ ជាកូនក្រមុំ គឺត្រូវបានរួបរួមដោយព្រះជាម្ចាស់តែមួយ នៅ ក្រោមព្រះវិញ្ញាណតែមួយ ជាព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ នៅក្នុងការរួបរួមដ៏ បរិសុទ្ធតែមួយនៃព្រះជាម្ចាស់ ដើម្បីក្លាយជាកូនក្រមុំដ៏បរិសុទ្ធមួយ សម្រាប់ព្រះ ជាម្ចាស់។ នោះគឺត្រូវណាស់។ រាងកាយរង់ចាំដូចជាកូនក្រមុំ មួយជា—ដូចជាកូនក្រមុំមួយរូប ដូចដែលយើងហៅខ្លួនរបស់យើង ថាជាកូនក្រមុំ។ សម្រាប់ពេលវេលានៃ

ការរួបរួមរបស់កូនក្រមុំ ក្រុមជំនុំគឺត្រូវរួបរួមគ្នា។ វាគួរតែ បង្កើតសេចក្ដីស្រឡាញ់ក្នុងចំណោមពួកយើង ដែលយើងពិត ជាពិបាកនៅឆ្ងាយពី ម្នាក់ផ្សេងទៀត។ នោះគឺពិតជាត្រឹមត្រូវណាស់។ យើងគ្រាន់តែ...អ្នកមិនចាំបាច់ សុំឲ្យមនុស្សអធិស្ឋាននោះទេអ្នកមិនចាំបាច់ សូមឲ្យពួកគេថ្វាយបង្គំព្រះនោះទេ អ្នកមិនចាំបាច់សូមឲ្យពួកគេធ្វើនូវអ្វីដែល ត្រឹមត្រូវនោះទេ។ ពួកគេត្រឹមតែមានសេចក្ដី ស្រលាញ់ក្នុងទ្រង់ហេតុទាល់តែមិនមាន អ្វីផ្សេងទៀតឡើយ។

114 តើគិតយ៉ាងដូចម្ដេចដែរអំពីក្មេងស្រីតូចមួយនេះជាក្មេងស្រីដ៏ស្រស់ស្អាតតូចម្នាក់ ដែលនិងរៀបការជាមួយបុរសវ័យក្មេងដ៏សង្ហាម្នាក់ ដែលនាងគឺទើបតែស្រឡាញ់គាត់ខ្លាំង វាមានន័យខ្លាំងសម្រាប់នាងជាង ជីវិតរបស់នាងទៅទៀត ហើយនាងដឹងយ៉ាងច្បាស់ថា នាងនិងរៀបការ។ ខណៈដែលថ្ងៃរៀបការបានមកដល់ក្មេងស្រីតូចនោះ ខ្ញុំកំពុងតែប្រាប់អ្នក នាងគឺ "កំពុងតែដើរជុំវិញ។" ឃើញទេ? នាងបានត្រៀមអ្វីៗទាំងអស់រួចរាល់ហើយ នាងបានចុះចូល ទាំងស្រុងជាមួយគាត់។ នោះគឺត្រូវហើយ។ គ្រប់អ្វីៗទាំងអស់ ដែលធ្វើ ឲ្យគាត់សប្បាយចិត្ត នោះគឺជាអ្វីដែលនាងចង់ធ្វើ។ ល្អ នោះគួរតែជាវិធី របស់ក្រុមជំនុំសព្វថ្ងៃនេះ ដោយជីវិតរបស់យើងគួរតែលាក់នៅក្នុងព្រះ តាមរយៈព្រះគ្រិស្ត ដោយបោះត្រានៅទីនោះដោយព្រះវិញ្ញាណបរិសុទ្ធ។

115 រឿងមួយខ្ញុំបានបង្រៀនអ្នកនៅទីនេះ គឺកំពុងតែប្រាប់អ្នកពីទីសម្គាល់ទាំងនេះនិងរឿងដែលកើតឡើងផ្សេងៗទៀត ខ្ញុំមិនមានពេលគ្រប់គ្រាន់ដើម្បីបង្រៀននៅពេលនេះទេ និងបង្រៀននៅព្រះបន្ទូលមួយទៀត ជាបំណងព្រះហឫទ័យរបស់ព្រះ ជាម្ចាស់។ ប៉ុន្តែមានរឿងតូចមួយ ដែលជាការខ្វះខាតនៅក្នុងក្រុមជំនុំ។ ហើយ យើងចង់ធ្វើបែបនោះ ដើម្បីទទួលបានការនោះ ហើយខ្ញុំគឺស្ថិតនៅចំពេលលើកិច្ចការនោះល្អណាស់ឥឡូវនេះ។ ឃើញទេ? យើងចង់ធ្វើកិច្ចការបែបនោះ ប្រសិន...អ្នកត្រូវតែធ្វើវា។ ប្រសិនបើអ្នកមិនចង់ធ្វើការនោះទេ ការទាំងអស់នោះ អ្នកត្រូវតែធ្វើវា។ សម្រាប់ការយកចិត្តទុកដាក់ ពេលវេលានៃការរួបរួមគឺមកដល់ហើយ សម្រាប់ព្រះជាម្ចាស់គឺការនាំឲ្យក្រុមជំនុំរួបរួមគ្នា—ជាសេចក្ដីរីករាយខ្លាំង ដើម្បីរៀបការ ជាការរួបរួមដ៏អស្ចារ្យមួយ នៅពេលព្រះជាម្ចាស់ និងមនុស្សរួបរួមគ្នាសម្រាប់ការអស់កល្បជានិច្ច នៅពេលរបស់មានជីវិតនៃពេលវេលារួបរួមជានិងភាពអស់ កល្បជានិច្ច។

116 ការនោះ ត្រូវបានសម្រេចនៅក្នុងទម្រង់ នៃកូនមនុស្សនៅលើផែនដី។ ហើយទ្រង់ត្រូវតែប្រទានព្រះជន្មទ្រង់ ដើម្បីនាំយកអំណាចមួយ ដើម្បីរួបរួមមនុស្សផ្សេងទៀត ជាមួយនិងអំណាចដូចគ្នានេះ សម្រាប់កូនក្រមុំនៃ ព្រះយេស៊ូគ្រិស្ត។ ហើយពេលនេះក្រុមជំនុំគឺកំពុងតែរួបរួមគ្នាក្លាយទៅជារាងកាយ មួយនៃព្រះគ្រិស្ត។ រាងកាយនោះទទួលបានសិរីភាព កាត់ផ្តាច់ចេញពីគ្រប់ចំណង ត្រៀមខ្លួនរួចជាស្រេច រួបរួមគ្នាក្នុងចំណោមពួកគេ អូ សេចក្តីស្រឡាញ់ និងអំណរ ហើយព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងចំណោមពួកគេ។ ឱ ខ្ញុំ អើយ ជាពេលមួយដ៏អស្ចារ្យ!

117 ខណៈពេលយើងឃើញសត្វទាត្រៀមខ្លួនរួចជាស្រេច យើងឃើញសត្វក្ងានត្រៀម ខ្លួនរួចជាស្រេច យើងឃើញសត្វឃ្មុំ...ឃ្មុំត្រៀមខ្លួនជាស្រេច យើងឃើញពពក ត្រៀមជាស្រេចដើម្បីភ្លៀង យើងឃើញគ្រប់កិច្ចការទាំងអស់ តើវារួបរួមគ្នាដោយរបៀបណា សម្រាប់ការជំរុញដ៏អស្ចារ្យរបស់វា។ យើងឃើញការរួបរួមជាតិពីប្រជាជាតិជាច្រើនរួមគ្នា ការរួបរួមគ្នាជាលទ្ធិកុំម្មុនីស្ត។ យើងឃើញពួកគេរួបរួមគ្នានៅ លោកខាងលិច។ យើងឃើញក្រុមជំនុំរួបរួមគ្នា គ្រប់ការទាំងនេះ។ ដូច្នេះវាគឺពិតជា មិនអាចទៅរួចទេ មិនមានពេលណាអាចធ្វើបានដូចពេលនេះទេ វាមិនអាច កើតឡើងបែបនេះអស់រយៈពេល២០ឆ្នាំហើយ មិនបានកើតឡើងបែបនេះទេ។ មិនបានកើតឡើងបែបនេះអស់ដប់ឆ្នាំហើយ ត្រូវតែកើតឡើងនៅពេលនេះ។ ឃើញទេ ដោយព្រោះជំនឿ និងការទាំងអស់មិនបានកើតឡើងបែបនេះទេ។

118 ឥឡូវនេះសូមក្រោកឡើង! អង្រួនខ្លួនរបស់អ្នកឲ្យលឿន ហើយមើលទៅទីនោះ តើយើងនៅកន្លែងណា! យើងនៅកន្លែងណា? ដូចជាអ្នកប្រាជ្ញទាំងនោះ យើងស្ថិតនៅក្នុងបន្ទាត់ដ៏ត្រឹមត្រូវជាមួយព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយពន្លឺរបស់ព្រះអម្ចាស់គឺកំពុងតែចាំងចែងលើផ្លូវរបស់យើង។ សូមសិរីរុងរឿងមានដល់ព្រះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត។ និងសូមសិរីរុងរឿងមានដល់ព្រះជាម្ចាស់ ជាអង្គដែលប្រទានព្រះយេស៊ូគ្រិស្តដល់យើង ជាអង្គដែលយើងស្រឡាញ់ និងបាននាំយកយើងមកកាន់ទីកន្លែងនេះ។ ហើយនៅពេលយើង...យើងជាមនុស្សរបស់ទ្រង់បាននាំមកជាមួយនូវតម្លៃឈាមរបស់ទ្រង់។

119 ឱ ខ្ញុំអើយ! នៅពេល ពេលវេលានៃការរួបរួមមកដល់ យើងកំពុងតែរង់ចាំដូច ដែលយើងរួបរួមជាមួយអ្នកផ្សេងទៀតនៅក្នុងព្រះវិញ្ញាណរបស់ទ្រង់ យើង...វាអាច ជាព្រះវិញ្ញាណរបស់ទ្រង់ទេ? ពិតណាស់ នោះគឺជាព្រះវិញ្ញាណរបស់ទ្រង់។

ហេតុ អ្វីនោះជាព្រះវិញ្ញាណរបស់ទ្រង់? នោះគឺជាព្រះបន្ទូលរបស់ទ្រង់ ហើយទ្រង់គឺជា... នោះហើយគឺជាវិញ្ញាណនៃព្រះបន្ទូល។ ហើយនៅពេលព្រះវិញ្ញាណនៃសេចក្តី សន្យានោះមកដល់អ្នក និងជាភស្តុតាង និងបង្ហាញខ្លួននៅពេលនេះ តើនោះគឺជា ព្រះវិញ្ញាណដូចគ្នាទេ? គឺជាព្រះវិញ្ញាណដែលនៅជាមួយលោកម៉ូសេនៅទីរហោស្ថាន! គឺជាព្រះវិញ្ញាណដែលនៅលើព្រះយេស៊ូគ្រិស្ត! គឺទ្រង់តែ មួយដែល ជួបលោកសូលនៅតាមផ្លូវរបស់គាត់ទៅកាន់ក្រុងដាម៉ាស! ទ្រង់គឺដ៏ដែល ពីម្សិលមិញ ថ្ងៃនេះ និងជារៀងរហូត! ហើយទ្រង់ធ្វើកិច្ចការដូចគ្នា!

120 ហើយយើងឃើញប្រជាជាតិរួបរួមគ្នា យើងឃើញក្រុមជំនុំរួមគ្នា យើងឃើញលទ្ធិកុម្មុនីស្តរួមគ្នា យើងឃើញជំនឿកំពុងរួបរួម យើងឃើញគ្រប់កិច្ចការទាំងនេះ ហើយឥឡូវយើងឃើញកូនក្រមុំរួបរួមជាមួយព្រះបន្ទូល។ ឱ ខ្ញុំ អើយ! វាជាពេលដែលពួកបរិសុទ្ធគួរតែងើបឡើង ដើម្បីរួបរួមជាមួយអ្នកកំពុងតែ រស់នៅ ដើម្បីទៅ និងរួបរួមជាមួយព្រះយេស៊ូគ្រិស្តសម្រាប់ការអស់កល្បជានិច្ច។

121 សូមឲ្យព្រះជាម្ចាស់ជួយដល់អ្នក ដល់គ្រប់គ្នា ដើម្បីរួបរួមជាមួយព្រះគ្រិស្ត នៅយប់នេះ យើងនិងថ្វាយអ្វីៗទាំងអស់ដែលជារបស់យើង អ្វីៗទាំងអស់ដែល យើងមាន ប្រលឹងរបស់យើង រាងកាយ និងគំនិតរបស់យើង ទៅកាន់ព្រះយេស៊ូ គ្រិស្ត និងរង់ចាំសម្រាប់ពេលវេលានៃការរួបរួមនោះ។

> នៅពេលសម្លេងត្រែរបស់ព្រះជាម្ចាស់បន្លឺឡើង និងមិនមាន
> ពេលទៀតឡើយ
> ហើយពេលព្រឹកបំបែកអស់កល្ប ពន្លឺ និងយុត្តិធម៌
> នៅពេលអ្នកស្លាប់នៅក្នុងព្រះគ្រិស្តរស់ឡើងនិងរួមគ្នានៅ
> ឯនាយ (ជាមួយកូនក្រមុំដែលនៅរស់) ជាមួយបងប្អូន
> ទាំងនោះ។

122 សូមក្រឡេកមើលទៅកាន់ការរួបរួម! ព្រះជាម្ចាស់កំពុងរួបរួមក្រុមជំនុំជាមួយព្រះបន្ទូលរបស់ទ្រង់ ព្រះបន្ទូលជាមួយក្រុមជំនុំ ដែលទាំងពីរនិងដូចគ្នា "និយាយបែប*នេះ* និងកើតមានឡើង។ ធ្វើបែប*នេះ* និងកើតមានឡើង។ គឺបែបនេះហើយ គឺជាខ្ញុំនៅចំពោះមុខអ្នក គឺជាខ្ញុំដែលបញ្ជាក់វា គឺជាខ្ញុំដែលនៅជាមួយអ្នក។" ត្រូវហើយ។

123 យើងឃើញថាឥឡូវពេលវេលាបានមកដល់ នៅពេលសម្លេងត្រែបាន បន្លឺឡើង ហើយមនុស្សបរិសុទ្ធទាំងនោះរស់ឡើងវិញនៅទីនោះ ពួកគេមិនអាចធ្វើបានឥតខ្ចោះដោយពុំមានយើងឡើយ ពួកគេគឺពឹងលើយើង (ហេព្រើជំពូកទី១១) ហើយនៅពេលពួកគេរួបរួមគ្នា ពួកគេរួបរួមគ្នាជាមួយអ្នក ដែលមានជីវិតរស់នៅ។ ក្រុមជំនុំមួយកំពុងរួបរួមជាមួយព្រះបន្ទូល ក្រោយមកក្រុមជំនុំនិងព្រះបន្ទូលរួបរួមគ្នាតែមួយ ក្លាយទៅជាតែមួយ។ អ្នកបរិសុទ្ធដែលស្លាប់ ជាមួយអ្នកបរិសុទ្ធដែលរស់នៅរួមគ្នាតែមួយ ហើយគ្រប់គ្នារួបរួម ដើម្បីរួមជាមួយព្រះគ្រិស្ត សម្រាប់ពិធីរៀបការដ៏អស្ចារ្យរបស់កូនចៀម។

124 វាគឺជាពេលវេលានៃការរួបរួមហើយទីសម្គាល់គឺមានគ្រប់ទីកន្លែង។ ទីសម្គាល់នោះគឺនៅក្នុងប្រជាជាតិ ទីសម្គាល់ក្នុងលទ្ធិកុម្មុនីស្ត ទីសម្គាល់នៅលោកខាងលិច ទីសម្គាល់នៅក្នុងក្រុមប្រឹក្សាក្រុមជំនុំ។ ហើយទីសម្គាល់គឺនៅទីនេះ យប់នេះនៅក្រោមអំណាចនៃព្រវិញ្ញាណបរិសុទ្ធ ហើយព្រះបន្ទូលរបស់ ព្រះជាម្ចាស់បញ្ជាក់ពីការនេះ និងការធ្វើឲ្យវាក្លាយទៅជាសេចក្តីពិត។ អាមែន! ពេលវេលានៃការរួបរួម! ទីសម្គាល់នៃពេលវេលានៃការរួបរួម!

សូមយើងទាំងអស់គ្នាឱនក្បាលចុះ។

125 ព្រះអម្ចាស់យេស៊ូដូចដែលចិត្តដ៏ទន់ខ្សោយរបស់ទូលបង្គំលោតឡើងសម្រាប់សេចក្តីអំណរដូចដែលទូលបង្គំឃើញភាពអាចទៅរួច នៃទូលបង្គំជាមនុស្សមានអាយុពាក់កណ្តាលទៅហើយប៉ុន្តែភាពដែលអាចទៅរួចរបស់ខ្ញុំ គឺឃើញទ្រង់ យាងមកនៅក្នុងជំនាន់នេះមានជីវិតនិងឈរនៅទីនេះ ហើយឃើញនៅពេលសម្លេងត្រែបានបន្លឺឡើង "អ្នកណាទុច្ចរិត អោយអ្នកនោះប្រព្រឹត្តអំពើទុច្ចរិតតទៅមុខទៀតទៅ រីឯអ្នកសុចរិតវិញ ត្រូវប្រព្រឹត្តអំពើសុចរិតថែមទៀតចុះ! រីឯអ្នកបរិសុទ្ធហើយ ត្រូវរក្សាខ្លួនអោយកាន់តែបរិសុទ្ធថែមទៀតចុះ។" អូ ព្រះ អម្ចាស់!

126 ហើយដើម្បីគិតពីយើងកំពុងតែឈរ នៅពេលនេះ នៅក្នុងការព្រិចភ្នែកដ៏ខ្លីនេះ នៅពេលពិភពលោកមិនបានដឹងពីអ្វីដែលកំពុងតែកើតមានឡើងឡើយ ប៉ុន្តែរំពេច នោះ អ្នកនិងឃើញអ្វីមួយលេចឡើងចំពោះមុខអ្នក អ្នកដែលអ្នកស្រឡាញ់ដែលមានទំនាក់ទំនង បានមករួបរួមជាមួយអ្នកម្តងទៀត។ ហើយយើងនិងបានផ្លាស់ប្តូរមួយរំពេច នៅក្នុងរយៈពេលមួយប្រព្រិចភ្នែក ហើយរួបរួមគ្នាឡើង ដើម្បី

ជួបជាមួយព្រះអម្ចាស់នៅលើមេឃ។ ហើយក្រោយមករួបរួមជាមួយទ្រង់ ដើម្បីនៅទីនោះជារៀងរហូត និងមិនចេញឆ្ងាយពីព្រះវត្តមានរបស់ទ្រង់ទៀតឡើយ។

127 នោះគឺជារឿងដ៏អស្ចារ្យនៅថ្ងៃនេះ ព្រះអម្ចាស់ ដើម្បីដឹងថាយើងពេលនេះរួបរួមជាមួយព្រះវិញ្ញាណតែមួយ។ ព្រះវិញ្ញាណមួយគឺជា ព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលក្នុងព្រះហស្ថ ចាក់មកកាន់យើង។ ហើយនោះគឺជារឿងដ៏អស្ចារ្យបំផុត ជាអភ័យឯកសិទ្ធិមួយ ដើម្បីកាត់ផ្តាច់ពិភពលោក ដែលមិនអាចគ្រប់គ្រងបាន ដើម្បីរួបរួមខ្លួនរបស់យើងជាមួយព្រះយេស៊ូគ្រិស្ត។ ហើយគិតថា នៅថ្ងៃណាមួយ ជាទម្រង់រូបកាយមួយ ជាមួយរូបរាងកាយ ដូចទ្រង់ទទួលបានរូបរាងមានសិរីរុងរឿង យើងនិងរៀបចំគុមង្គលការដ៏អស្ចារ្យ និងត្រូវបានរួបរួម ហើយនិងរៀបមង្គលការជាមួយទ្រង់ ដើម្បីរស់នៅជាកូនក្រមុំ និងកូនកម្លោះជារៀងរហូត ដែលនិង មកដល់តាមរយៈភាពអស់កល្បឥតឈប់ឈរ។

128 ព្រះជាអម្ចាស់ នេះមិនគ្រាន់តែជាការដែលមិនពិតតាមការគិតរបស់មនុស្សឡើយ ប៉ុន្តែសូមឲ្យការនេះក្លាយទៅជាការពិត រហូតទាល់តែសេចក្តីស្រេកឃ្លាននិងមានដល់មនុស្ស ដែលពួកគេនិង...កំពុងតែអានកាសែតរបស់ពួកគេ កំពុងសម្លឹងមើល...កំពុងស្តាប់វិទ្យុ និងព័ត៌មាន ហើយកំពុងតែឃើញពេលវេលានៃការរួបរួម។ ទីសម្គាល់កំពុងបង្ហាញពន្លឺឡើង។

129 ព្រះជាអម្ចាស់ ដូចដែលយើងបាននិយាយពីស្រ្តីទាំងនោះ តើពួកគេនិងធ្វើអ្វីនៅថ្ងៃចុងក្រោយ តើក្រុមជំនុំនិងធ្វើអ្វីនៅថ្ងៃចុងក្រោយ ហើយតើសម័យកាលក្រុមជំនុំនិងក្លាយជាយ៉ាងណា ហើយតើ គ្រានិងក្លាយជាយ៉ាងណា គ្រប់កិច្ចការអស់ទាំងនេះ។ ហើយយើងឃើញដូចជាថ្ងៃលោកណូអេ។ យើងឃើញដូចនៅថ្ងៃក្រុង សុដុម និងលោកឡុតនៅ ពេលទេវតានៃព្រះជាម្ចាស់បានធ្វើឲ្យអង្គទ្រង់ស្គាល់ជាសាច់ឈាមមនុស្ស ដែល បរិភោគសាច់គោ និងផឹកទឹកដោះគោពីសត្វគោ ហើយបរិភោគនំបុ័ង និង ឈរ នៅទីនោះ ហើយអាចប្រាប់ពីអ្វីដែលនឹងកើតនឡើងពីក្រោយទ្រង់។ ហើយ ព្រះយេស៊ូមានបន្ទូលដូចគ្នា នឹងកើតមានឡើងនៅពេល បុត្រមនុស្សយាងមក។

130 ព្រះជាអម្ចាស់បានយើងឃើញពីរ៉ាមីត ថាតើយើងសាងសង់វាឡើងដោយរបៀបណា ហើយថាតើយើងបន្ថែមការទាំងនេះដោយរបៀបណា ហើយ ឃើញថាយើងស្ថិតនៅពេលចុងក្រោយរង់ចាំថ្មគ្រឹះជ្រុងយ៉ាងឯក។ ថ្វាយសិរីរុងរឿងដល់

ព្រះជាម្ចាស់! យើងអធិស្ឋានព្រះវរបិតា ដែលទ្រង់នឹងដាស់មនុស្សឲ្យភ្ញាក់ឡើងឲ្យលឿន ឥឡូវនេះ និងប្រមូលយើងរួមគ្នា ជាមួយសេចក្តីស្រឡាញ់របស់ព្រះ និងការគោរពទៅកាន់ព្រះយេស៊ូគ្រិស្ត និងទៅកាន់គ្នាទៅវិញទៅមក។

131 ប្រសិនបើមានមនុស្សខ្លះនៅទីនេះ យប់នេះ ដែលមិនមានក្តីសង្ឃឹមនៅក្នុងអ្នក សូមអ្នកលើកដៃឡើងទៅកាន់ព្រះជាម្ចាស់ ហើយនិយាយថា "ព្រះជាអម្ចាស់ សូមរួបរួមទូលបង្គំជាមួយទ្រង់ សូមរួបរួមទូលបង្គំជាមួយទ្រង់"? សូមព្រះប្រទានពរដល់អ្នក បងប្អូនអើយ។ សូមព្រះប្រទានពរអ្នក និងអ្នក អ្នក ហ្នឹង។ "សូមរួបរួមទូលបង្គំជាមួយទ្រង់ព្រះអម្ចាស់អើយ។" បាទ! ឱខ្ញុំអើយ!

## ប្រជាជាតិ កំពុងតែបែកបាក់ អ៊ីស្រាអែលកំពុងតែភ្ញាក់

132 សូមមើលទៅកាន់អ៊ីស្រាអែលនៅទីនោះ បានរួបរួមគ្នា។ អ៊ីស្រាអែល ទូទាំងពិភពលោក ត្រូវមកដើម្បីរួបរួមគ្នា ដើម្បីរួបរួមគ្នា ហើយឥឡូវពួកគេជាប្រជាជាតិមួយ។ ពួកគេបានរួបរួមប្រជាជាតិ ជាមួយទង់ជាតិរបស់ពួកគេ លុយរបស់ពួកគេ កងទ័ពរបស់ពួកគេ គ្រប់អ្វីៗទាំងអស់ ប្រសិនបើពួកគេធ្លាប់ធ្វើ បែបនោះ ពួកគេអាចធ្វើពេលនេះ។ អ៊ីស្រាអែលបានរួបរួម រ៉ូមគឺត្រូវបានរួបរួម ក្រុមជំនុំត្រូវបានរួបរួម។ ហើយកូនក្រមុំគឺកំពុងរួបរួម អាម៉ែន និងការមកដល់នៃការរួបរួមដ៏អស្ចារ្យ។ តើនេះគឺជាអ្វី? នោះគឺជាការធ្វើចលនាទៅកាន់ទីសម្គាល់នោះ នោះគឺជាទីសម្គាល់ដ៏ចម្បង ព្រះយេស៊ូ និងកូនក្រមុំរបស់ទ្រង់កំពុងតែរួបរួមគ្នា តែមួយ។

133 ព្រះវរបិតា ព្រះជាម្ចាស់ សូមប្រទានព្រះពរការនេះដែល ទូលបង្គំសូមសម្រាប់មនុស្សទាំងអស់នេះ ហើយសូមឲ្យយើងត្រូវបានរួបរួមគ្នា សម្រាប់ទ្រង់នៅក្នុងចិត្ត និងវិញ្ញាណដូចដែលពួកគេលើកដៃឡើងសម្រាប់បំណងចិត្តនោះ។ ព្រះជាអម្ចាស់ សូមសម្អាតយើង និងធ្វើឲ្យយើងក្លាយជាកម្មសិទ្ធិទ្រង់ សូមទទួល ព្រះជាម្ចាស់អើយ។ នោះជាអ្វីដែលយើងដឹង ហើយយើងអាចធ្វើបានគឺសុំ។ ហើយទ្រង់បានមានបន្ទូលថាប្រសិនបើយើងសូមដោយជំនឿ យើងនឹងទទួលបាន ទូលបង្គំរង់ចាំការនោះព្រះអង្គអើយ។ ទូលង្គំសូមអរព្រះគុណទ្រង់ នៅក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត។ អាម៉ែន។

ខ្ញុំស្រឡាញ់ទ្រង់ ខ្ញុំស្រឡាញ់ទ្រង់
ព្រោះទ្រង់ស្រឡាញ់ខ្ញុំមុន
ហើយបានទិញសេចក្តីសង្គ្រោះខ្ញុំ
នៅដើមកាល់វ៉ារី។ (អាម៉ែន។ អូ ខ្ញុំអើយ!)

ចូរប្រុងស្មារតីកូនកម្លោះនឹងមកដល់!
ខ្ញុំឮកណ្តាលអធ្រាត្រមានអ្នកស្រែកឡើងថា!
យើងនិងស្រែកឡើង ប្រសិនបើយើងត្រៀមខ្លួនជាស្រេច
ហើយជួបទ្រង់នៅលើមេឃ។

សូមប្រយ័ត្ន និងអធិស្ឋាន បងប្អូន
កុំអោយនរណាដណ្តើមមកុដអ្នកបាន
ដ្បិតអ្នកនៅឧណ្ឌៗ និងអ្នកបែរចេញ
មិនអាចពាក់មកុដរៀបការបានឡើយ។

134 ត្រូវហើយ។ សូមត្រៀមខ្លួនជាស្រេចសម្រាប់សម្រែក ពាក់កណ្តាលអធ្រាត្រ។ វានិងមកដល់ក្នុងពេលមួយម៉ោងនេះ នៅពេលអ្នកគិតថា មិនកើតឡើង។ នឹងមានការស្រែកឡើង មិនមែនក្នុងចំណោមអ្នកមិនជឿក្នុងពិភពលោកនេះទេ វាជាការសម្ងាត់។ ប៉ុន្តែអ្នកជឿ ជាអ្នកដែលកំពុងរង់ចាំការ នេះ អ្នកឃើញផ្កាយតម្រៀបជាជួរ? ឃើញទេ? តើវាបង្កើតបានជាអ្វី? គឺពិត ប្រាកដដូចជាផ្កាយនេះបានធ្វើជាលើកទីមួយ។ ឃើញទេ នេះហើយគឺជាទីសម្គាល់ ដែលកំពុងតែមក។

យើងឃើញទីសម្គាល់កំពុងតែលេចឡើងនៃព្រះពរទ្រង់មក
មើលស្លឹក ដើមឧទុម្ពរពេលនេះក្លាយ ទៅជាពណ៌ បៃតង
ដំណឹងល្អនៃអាណាចក្របានទៅដល់គ្រប់ប្រជាជាតិ
ហើយយើងនៅជិត ចុងបញ្ចប់អាចនឹងឃើញ។

បន្ទាប់មកការរីករាយត្រូវរលាយបាត់យើងនិងឃើញ
អ្នកនាំសារមុននៃព្រះពរនឹងលេចឡើង។

135 តើនោះត្រូវទេ? អូអ្នកនាំសារមកមុននៃព្រះពររបស់ទ្រង់កំពុង លេចឡើងហើយ! នោះហើយជាអ្វីដែលយើងត្រូវតែធ្វើ។ ប្រាប់គ្រប់គ្នា "ត្រៀមខ្លួន ជាស្រេចដើម្បីជួបជាមួយព្រះជាម្ចាស់។" អាម៉ែន! ខ្ញុំស្រឡាញ់ទ្រង់។ អូ ខ្ញុំស្រឡាញ់ទ្រង់

ណាស់។ ឥឡូវ សូមយើងក្រោកឈរឡើង។ ខណៈពេលយើង ស្វាគមន៍ អ្នកដទៃនៅជុំវិញនិងចាប់ដៃជាមួយអ្នកផ្សេងទៀត ហើយនិយាយថា

រហូតដល់យើងជួប!(ចាប់ដៃឥឡូវ)...រហូតល់យើងជួប!
រហូតដល់យើងជួបនៅព្រះបាទព្រះយេស៊ូ
រហូតដល់យើង...

សូមចងចាំ អ្នកអាចនិងមានការត្រាស់ហៅ។ ការប្រជុំរបស់យើងនៅពេលក្រោយអាចនៅឯព្រះបាទាទ្រង់។

ឱព្រះគង់ជាមួយអ្នកទាល់តែយើងជួបគ្នាម្តងទៀត!

136 ពេលនេះ គ្រាន់តែគិត មុនពេលយើងជួបគ្នាម្តងទៀត មុនពេលយើងជួបគ្នានៅព្រឹកថ្ងៃអាទិត្យ ឬក៏នៅយប់ថ្ងៃពុធ ប្រហែលជាបែបនោះ...ការមួយអ្នកដឹងទេ គឺមានអ្នកបាត់ខ្លួន។ ម្នាក់នេះបានបាត់ខ្លួន ហើយពួកគេបានចេញទៅឆ្ងាយ។ អូ ដើម្បីគិតពីប្តីរបស់អ្នកបាត់ខ្លួន ឬក៏ប្រពន្ធរបស់អ្នក ហើយ—ហើយ ប្រពន្ធលោកចនបាត់ខ្លួន ហើយ—ហើយ—នៅទីនោះក្មេងៗក៏បាត់ខ្លួនដែរ។ គ្រប់ការទាំងនេះបានកើតឡើង (តើមានអ្វីជំនួស?) ក្រោយមកអ្នកបានបន្សល់វាទុក!

អូ  ការឈឺចាប់និងសម្រែកថ្ងូរនៅពេលអ្នកបាត់បង់បាន
ប្រាប់ពីជោគវាសនារបស់ពួកគេ
ពួកគេយំទៅកាន់ថ្ម និងភ្នំ (ដូចជាអ៊ីស្រាអែលនៅតាមផ្លូវ
ត្រឡប់ទៅកាន់ទីក្រុង ទៅកាន់ព្រះវិហារ។)
ពួកគេអធិស្ឋាន ប៉ុន្តែការអធិស្ឋានរបស់ពួកគេគឺ យឺតពេល
ហើយ។ (ពួកគេ បានបដិសេធព្រះបន្ទូល។)

137 អូបងប្អូនអើយ កុំធ្វើបែបនោះ។ អ្វីក៏ដោយដែលអ្នកធ្វើ មានជំហរជាមនុស្សមានមូលហេតុ! ត្រូវហើយ!

138 ឥឡូវ ទាល់តែយើងជួបគ្នា យើងនិងធ្វើកិច្ចការនេះ:

ចូរយកព្រះនាមព្រះយេស៊ូជាមួយ
ទុកជាខែល ការពារទាំងអស់
ពេលមេល្បួងឡោមព័ទ្ធនាំឲ្យព្រួយ (តើអ្នកនិងធ្វើអ្វី?)
ត្រូវតែរកព្រះនាមដ៏ពិត។

នាមវិសេស នាមប្រសើរ!
គឺជាទីសង្ឃឹមដល់មនុស្ស។
នាមវិសេស នាមប្រសើរ!
ជាព្រះនាមនៃព្រះដ៏រស់។

139 សូមយើងឱនក្បាលចុះនៅពេលនេះ ខណៈពេលយើងច្រៀងតិចៗ។

ឱព្រះនាមវិសេសវិសុទ្ធនោះ
នោះនឹងក្រាបចុះថ្វាយបង្គំ
ស្តេចលើ ស្តេច ស្ថានសួគ៌...អភិសេកទ្រង់
នៅពេលដំណើរ យើងសម្រេច។(វានឹងនៅ ថ្ងៃណាមួយ។)

នាម វិសេស នាមវិសេស នាមប្រសើរ!

រហូតទាល់តែយើងជួបគ្នាម្តងទៀត សូមព្រះគង់នៅជាមួយអ្នក។

គឺជាទីសង្ឃឹមដល់មនុស្ស
នាមវិសេស នាមប្រសើរ! នាមប្រសើរ!
ជាព្រះនាមនៃព្រះដ៏រស់។

**ពេលវេលានៃការរួបរួម និងទីសម្គាល់** KHM63-0818

(The Uniting Time And Sign)

សារដែលធ្វើឡើងដោយបងប្រុស William Marrion Branham នេះ ត្រូវបានចែកចាយនៅល្ងាច ថ្ងៃអាទិត្យ ថ្ងៃទី 18 សីហា 1963 នៅរោងឧបោសថBranham, Jeffersonville, Indiana, U.S.A។ រាល់ការខិតខំត្រូវបានធ្វើឡើងដោយការផ្ទៀងផ្ទាត់យ៉ាងត្រឹមត្រូវ ជាសារសម្លេងចេញពីខ្សែអាត់ថត ចម្លង និង បោះពុម្ពដោយរក្សាសិទ្ធពីភាសារអង់គ្លេស។ ការបក ប្រែជាភាសារខ្មែរនេះ គឺត្រូវបោះពុម្ព និង ចែកចាយដោយ សម្លេងព្រះជាម្ចាស់ដែលបានថតទុក។

KHMER

©2020 VGR, ALL RIGHTS RESERVED

VOICE OF GOD RECORDINGS
P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.
www.branham.org

## ការរក្សាសិទ្ធ

សៀវភៅនេះត្រូវបានរក្សាសិទ្ធ។ សៀវភៅនេះអាចថតចម្លង បានជាការប្រើប្រាស់ផ្ទាល់ខ្លួន ដោយសេរី ឥតគិតថ្លៃ ដើម្បីផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រិស្ត។ សៀវភៅនេះ មិនអាចលក់ ផលិតជាទ្រង់ទ្រាយធំ យកទៅដាក់ក្នុងវេបសាយ លក់តាមប្រព័ន្ធអេលេចត្រូនីក ឬ បកប្រែ ដោយគ្មានការអនុញ្ញាតិពី វ៉យ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS®.)ឡើយ។

សម្រាប់ទំនាក់ទំនងបន្ថែម និង ឬសម្រាប់តម្រូវការទាក់ទងនឹងឯកសារសូមទំនាក់ទំនង៖

វ៉យស៍ អូហ្វ ហ្គត់ រីខខតឌីង (VOICE OF GOD RECORDINGS)

P.O. BOX 950, JEFFERSONVILLE, INDIANA 47131 U.S.A.

WWW.BRANHAM.ORG